OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Mar-2017, 14:42
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ - កោសល្យុប

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:២២នាទី**

**សវនាការលើកទី៣៦៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក នីកូឡូ ប៉ុងស៍*(Mr. Niccolo PONS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆរ័ន្ត

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី គួច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោក ឡេា ជុនធី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ព្រុំ សារ៉ាត (2-TCW-1009) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ព្រុំ សារ៉ាត** (2-TCW-1009)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................................................ ទំព័រ ៣
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី.................................................... ទំព័រ ៣១

# កិច្ចដំណើរការនីតិវិធី

[០៩:២២:៤០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

បាទ អង្គុយចុះ!

បាទ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមជម្រាបជូនភាគី និងសាធារណជនជ្រាបថា ដោយព្រឹកនេះ លោក ខៀវ សំផន គាត់មានបញ្ហាសុខភាព ដោយសម្ពាធឈាមឡើងខ្ពស់ ហើយតាមមតិយោបល់របស់គ្រូពេទ្យប្រចាំការ គាត់បានវាយតម្លៃថា ស្ថានភាពមានអារម្មណ៍វិលជួលចិត្តខ្លាំងនាពេលនេះ អាចនឹងធម្មតាឡើងវិញ នៅរយៈពេលប្រហែលជាកន្លះម៉ោង ឬទៅមួយម៉ោង។ អ៊ីចឹងហើយអង្គជំនុំជម្រះមិនធ្វើសវនាការនៅក្នុងអំឡុងពេលនេះទេ អង្គជំនុំជម្រះនឹងចាប់ផ្តើមធ្វើសវនាការនៅព្រឹកនេះ ចាប់ផ្តើមពីម៉ោងដប់កន្លះ សូមភាគី និងសាធារណៈជ្រាបអំពីបញ្ហានេះ។

ឥឡូវសម្រាកសិនចុះ ម៉ោងដប់កន្លះ យើងចូលវិញដើម្បីចាប់ផ្តើមសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:២៣ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:០៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ព្រុំ សារ៉ាត ហើយនិងមានសាក្សីបម្រុង 2-TCW-889។ ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ាយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល

ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក ព្រុំ សារ៉ាត។ លោក និងមេធាវីប្រឹក្សារបស់លោក មានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-849។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[១០:៣៣:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊យ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថាដោយសារគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខ ឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដោយធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺខ្នង និងឈឺចង្កេះរ៉ាំរ៉ៃ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១០:៣៥:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ <មុននឹង>ខ្ញុំ<>សួរលោកអំពីបញ្ហាបូរណភាពដែនដីនៃកម្ពុជាប្រជាធិបតេយ្យ គឺថាដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ <ខ្ញុំសូមត្រឡប់ទៅពិនិត្យមើលប្រធានបទដែល>យើង<>បាន<ពិភាក្សាកាលពីម្សិលមិញ មុនពេល>ផ្អាកសវនាការ។ ម្សិលមិញ<លោក>បាននិយាយ<>អំពីកងទ័ពចំនួន៧០០នាក់ មកពីភូមិភាគបូព៌ានៅក្នុងកងពល១៦៤។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក <សំណួរចម្លើយ> A-166 លោកបាននិយាយអំពីសហការីរបស់លោកដែលជាសមាជិកនៅក្នុងកងពល១៦៤។ លោកហៅគាត់ថា <ឈាន> នេះសព្វថ្ងៃរស់នៅក្បែរផ្ទះរបស់លោកនៅឯសំឡូត។ លោកនៅចាំទេ លោកបាននិយាយអំពីអតីតសមាជិកកងពល១៦៤ ឈ្មោះ <ឈាន> ដែលរស់នៅក្បែរ -- ឈ្មោះ ឈាន រស់នៅក្បែរផ្ទះរបស់លោកនៅសំឡូត?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** បាទ ឈ្មោះ ឈាន គាត់រស់នៅជិតខ្ញុំនៅសំឡូត ជាអតីតអង្គភាពនៅជាមួយអង្គភាពអនុសេនាធំរបស់ខ្ញុំ។ សព្វថ្ងៃគាត់នៅរស់។

[១០:៣៦:៥១]

**ស៖** តើគាត់មកពីបូព៌ា ឬក៏គាត់មកពីភូមិភាគនិរតី?

**ឆ៖** បូព៌ា គាត់មកពីភូមិភាគបូព៌ា។

**ស៖** លោកនៅចាំទេថាមានពេលមួយនោះ ឈាន ត្រូវបានបញ្ជូនទៅការដ្ឋានសាងសង់ព្រលានយន្តហោះពោធិ៍ចិនតុង -- ព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆ៖** តាមការជួបគាត់ក្រោយមក គាត់បានប្រាប់ខ្ញុំថា គាត់ទៅបំពេញភារកិច្ចនៅព្រលានយន្តហោះថ្មីកំពង់ឆ្នាំង។ ហើយគាត់បានបញ្ជាក់ប្រាប់ខ្ញុំថា គាត់សោកស្ដាយដោយសារគាត់បែកពីខ្ញុំ គាត់មានមនោសញ្ចេតនាជ្រាលជ្រៅជាមួយខ្ញុំ ហើយគាត់គិតថា ខ្លួនគាត់មានភាពបែកពីខ្ញុំដោយមិនបានដឹងខ្លួនថា តើគេបញ្ជូនគាត់ចេញទៅណា។

**ស៖** តើ ឈាន នេះ<គ្រាន់តែ>ជាកងទ័ពម្នាក់ក្នុងចំណោមកងទ័ពទាំង៧០០នាក់មកពីភូមិភាគបូព៌ា<ដែលត្រូវបានគេបញ្ជូនទៅកំពង់ឆ្នាំង> ឬក៏លោកនៅដឹងថា មានកងទ័ពមកពីភូមិភាគបូព៌ាណាខ្លះទៀតត្រូវបានបញ្ជូនទៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនោះដែរទេ?

**ឆ៖** រឿងនេះឈ្មោះ ឈាន គាត់អត់បានបញ្ជាក់ប្រាប់ខ្ញុំថាតើមាននរណាទៅជាមួយគាត់ពេលដែលខ្ញុំជួបគាត់ អត់បានបញ្ជាក់ឈ្មោះថា តើអ្នកណាខ្លះដែលទៅជាមួយទេ។

**ស៖** តើសព្វថ្ងៃនេះគាត់នៅរស់រានមានជីវិតទេ?

**ឆ៖** សព្វថ្ងៃគាត់នៅរស់។

[១០:៣៩:០៨]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំបន្តចូលទៅនិយាយអំពីដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យចន្លោះពីឆ្នាំ<១៩៧៦ ឬ>១៩៧៥ ដល់៧៩។ ឥឡូវខ្ញុំសូមសួរសំណួរទូទៅសិន។ លោកនៅចាំទេថា មានអ្វីកើតឡើងនៅក្នុងបណ្ដាឆ្នាំទាំងនោះ បើសិនណាជាមានទូក ឬក៏កប៉ាល់ណាមួយចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ឬក៏មកកៀកនឹងកោះណាមួយ ដូចជាកោះពូលូវ៉ៃជាដើម តើមានអ្វីកើតឡើងទៅដល់<អ្នកជិះលើ>ទូក កប៉ាល់ដែលចូលមកក្នុងដែនទឹក ឬមកជិតដែនកោះទាំងនោះ?

**ឆ៖** តាមខ្ញុំចាំ នៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ធម្មតាអធិបតេយ្យភាពរបស់ដែនទឹកកម្ពុជា គឺខ្ញុំបានប្រើប្រាស់ផែនទី តែមកដល់ថ្ងៃនេះខ្ញុំមិនកំណត់ថា អធិបតេយ្យហ្នឹងមានចម្ងាយប៉ុន្មានពីកោះ ហើយខ្សែស្របប៉ុន្មាន ខ្សែទទឹងប៉ុន្មាន តាមរយៈនេះ ខ្ញុំចាត់ទុកថា ទាល់តែមានផែនទីមើល ទើបខ្ញុំដឹងថា ពេល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះយើងកំណត់អធិបតេយ្យត្រង់ណា។ ព្រោះបច្ចុប្បន្ននេះ គឺខ្ញុំចាំមិនបានថា វាជាអធិបតេយ្យនៅជិតឆ្ងាយទីណា មិនដឹងទេ។ តែខ្ញុំស្គាល់ថា កោះពូលូវៃចាស់ ពូលូវៃថ្មី កោះតាង កោះសេះ កោះរ៉ុងសន្លឹម ហើយនិងកោះរ៉ុងធំ វាជាដែនកោះរបស់កម្ពុជានៅចំណុចក្រៅ ឆ្ងាយជាងគេគឺកោះប៉ូឡូប៉ាន់ហ្សង់ ហៅថា កោះក្រចកសេះ។

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំសួរឲ្យបានជាក់លាក់តែម្តង។ តើនឹងមានអ្វីកើតឡើង ប្រសិនបើមានទូកណាមួយចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ហើយនៅលើទូកនោះ គឺថាមានជនជាតិវៀតណាមអាចជាជនភៀសខ្លួន អាចជាអ្នកនេសាទ ឬក៏ជាទូកដឹកកងទ័ពតែម្តង? ដូច្នេះតើលោកអាចជម្រាបជូនតុលាការបានទេ តើមានអ្វីកើតឡើងទៅដល់ទូកទាំងហ្នឹង ដែលមានមនុស្សទាំងអស់នេះនៅលើទូក បើសិនជាទូកទាំងនោះចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ?

[១០:៤២:០១]

**ឆ៖** ខ្ញុំសូមជម្រាបលោក អង្គសវនាការឲ្យច្បាស់ថា នៅដើមឆ្នាំ១៩៧៥ ដែនកោះរបស់កម្ពុជាពេលនោះមានការប្រយុទ្ធមួយយ៉ាងក្តៅ រវាងកងទ័ពវៀតណាម និងកងទ័ពកម្ពុជា ដោយប្រយុទ្ធ ចាប់កងទ័ពកម្ពុជាប្រជាធិបតេយ្យនៅលើកោះអស់ កោះចាស់ កោះពូលូវៃចាស់ និងកោះពូលូវៃថ្មី យកទៅវៀតណាមយកទៅដាក់នៅក្រោះត្រល់។ ហើយក្រោយមកការប្រយុទ្ធនេះបានបញ្ចប់ដោយថ្ងៃណា ខ្ញុំអត់ចាំទេ គ្រាន់តែខ្ញុំដឹងថា នៅចុងឆ្នាំ៧៥។

**ស៖** សូមអរគុណចំពោះចម្លើយនេះ។ ឥឡូវនេះ ខ្ញុំសូមផ្តោតទៅលើជនភៀសខ្លួនជនជាតិវៀតណាម ឬក៏អ្នកនេសាទជនជាតិវៀតណាម។ បើពួកគេនៅលើទូក ហើយចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ តើគេណែនាំឲ្យលោកធ្វើយ៉ាងម៉េចជាមួយអ្នកទាំងនេះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ចំពោះទូកនេសាទ និងទូកអ្វីផ្សេងទៀត ដែលមកចូលដល់ដែនទឹកជិតតំបន់គ្រប់គ្រងរបស់កងទ័ព ពេលនោះខ្ញុំបាទអត់ឈរជើងនៅលើកោះទេ សកម្មភាពរបស់ខ្ញុំ គឺធ្វើការងារហ្វឹកហ្វឺននាវានៅកំពង់ផែ សំចតនាវារបស់ខ្ញុំនៅអូរឈើទាល។ ដូច្នេះខ្ញុំអត់មានភារកិច្ចអីទៅបំពេញនៅដែនកោះទាំងអស់នោះទេ។

**ស៖** ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកបន្តិច ហើយដោយសារតែពេលវេលាផង ដូច្នេះខ្ញុំសូមចូលទៅចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា E3/9113 នៅពីរទំព័រ<ផ្សេងគ្នា> ទំព័រទី១ អង់គ្លេស ERN 0097206*(ស៊ីក)*, ខ្មែរ 00926384 មិនមាន ERN ជាភាសាបារាំងទេ។

នៅត្រង់ទំព័រនេះនៃចម្លើយរបស់លោក លោកបានឆ្លើយថា លោកនិយាយអំពីកងទ័ពវៀតណាម៖ "យើងបានចាប់<និងសួរចម្លើយ>ពួកគេ។ យើងបានដោះលែងជនភៀសខ្លួន។ បើសិនណាជាគេមិនឆ្លើយនឹងសំណួរយើង ហើយព្យាយាមលាក់អត្តសញ្ញាណរបស់ពួកគេ យើងនឹងបញ្ជូនពួកគេមកមន្ទីរសន្តិសុខ។"

<ហើយនៅក្រោមបន្តិចមមកទៀត> ERN ជាភាសាអង់គ្លេស 00974222, ខ្មែរ 00926399 លោកនិយាយអំពីជនភៀសខ្លួនជនជាតិវៀតណាម ឬក៏អ្នកទេសាទជនជាតិវៀតណាម។ ហើយលោកបានឆ្លើយថាដូចតទៅ៖ "គេបានបញ្ជាឲ្យយើងមិនឲ្យចាប់ជនស៊ីវិលទេ។ យើងអាចចាប់ពួកគេ ដើម្បីសួរព័ត៌មានលម្អិត ចង់ដឹងថាតើពួកគេជាជនភៀសខ្លួនមែនឬក៏អត់។ បើសិនណាជាគេ ពួកគេ<ចង់>ចាកចេញដោយសុវត្ថិភាព យើងអនុញ្ញាតឲ្យពួកគេចេញបាន។ ហើយយើងក៏អាចបញ្ជូនអាហារទៅឲ្យពួកគេផងដែរ។" តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ លោកសាក្សី?

[១០:៤៦:១១]

**ឆ៖** ចំណុចនេះ សូមរំឭកថា ខ្លួនខ្ញុំបានមានមតិជម្រាប ឡុង ដានី នៅពេលដែលគាត់សម្ភាសខ្ញុំនៅតាមវាលស្រែ។ ជាការបញ្ជាក់ឲ្យឃើញថា ខ្លួនខ្ញុំបានជម្រាប ឡុង ដានី តាមរយៈការថតសំឡេង។

**ស៖** តើលោកកំពុងតែអះអាងបញ្ជាក់ជូនតុលាការនេះនៅពេលនេះ <នូវអ្វីដែលខ្ញុំទើបតែអានឲ្យលោកស្តាប់ តើនេះជាអ្វីដែលលោកបាននិយាយឬ ហើយ>តើវាត្រឹមត្រូវអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ខ្ញុំសូមរៀបរាប់លម្អិតបន្តិចអំពីប្រធាននេះ ហើយនិងសូមអានឲ្យលោកស្តាប់ <នូវអ្វីដែល>មេបញ្ជាការកង<>អនុសេនាធំមួយទៀតនៃកងពល១៦៤<បាននិយាយ។ គាត់ឈ្មោះ [redacted]> គាត់គឺជាប្រធាន<ស្តីទី>នៃកងអនុសេនាធំ<លេខ៤>នៃ<វរសេនាតូចលេខ៤៥០>។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ លោកប្រធាន គឺឯកសារ E319/23.3.12។ សំណួរចម្លើយលេខ ៧៥ គាត់បានឆ្លើយដូចតទៅ គាត់និយាយអំពីទូកវៀតណាមដែលផ្ទុកទៅដោយជនភៀសខ្លួន ហើយគាត់បាននិយាយថា ខ្ញុំសូមដកស្រង់៖ "សុន សេន បាននិយាយថា បើជនជាតិវៀតណាមទាំងនោះជាជនភៀសខ្លួនធ្វើដំណើរទៅថៃ កុំចាប់ពួកគេ ហើយឲ្យពួកគេធ្វើដំណើរតទៅមុខទៀតចុះ។" បញ្ចប់ការដកស្រង់។ តើលោកមាននៅចាំថាមានការបញ្ជាមួយពី សុន សេន ទៅដល់កងពល១៦៤ថា ជនភៀសខ្លួនជនជាតិវៀតណាមមិនត្រូវចាប់ពួកគេទេ ហើយអនុញ្ញាតឲ្យពួកគេធ្វើដំណើរតទៅទៀតចុះ? តើលោកនៅចាំទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៤៨:៣៦]

**ឆ៖** បាទ រឿងនេះវាជាកិច្ចបញ្ជារបស់ថ្នាក់លើទៅកងពល។ សម្រាប់ខ្លួនខ្ញុំនៅបំពេញភារកិច្ចជាអ្នកកងទ័ពហ្វឹកហ្វឺនបច្ចេកទេស មិនមានទទួលបញ្ជាណាមួយចេញពីកងពលថា ឲ្យធ្វើយ៉ាងណាៗទេ ព្រោះខ្ញុំបំពេញភារកិច្ចជាសិស្សហាត់រៀនប្រើប្រាស់បច្ចេកទេស ដែលទើបតែនឹងទទួលបានជាជំនួយរបស់មិត្តចិន។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែថាតើពិតជាមានការបញ្ជាជាក់លាក់ពី សុន សេន ថាជនជាតិវៀត-ណាមនៅលើទូកទាំងនោះ បើសិនណាជាមិនមែនជាកងទ័ពទេ បើពួកគេជាជនភៀសខ្លួន ឬក៏ជាអ្នកនេសាទ គឺត្រូវអនុញ្ញាតឲ្យពួកគេបន្តដំណើរទៅមុខទៀត ទៅទិសដៅដែលពួកគេចង់ទៅ? តើអ៊ីចឹងឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំបានពិនិត្យផ្ទៀងផ្ទាត់មើលឯកសារ E319/23.3.12 គឺជាកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលយើងបានបង្ហាញជូនភាគីនៅខែមិថុនា ឆ្នាំ២០១៥។ ខ្ញុំមើលទៅដូចជាមេធាវីក្ដីមិនបានដាក់សុំឯកសារនេះជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះទេ។ លើកលែងតែខាងមេធាវីការពារក្ដីបានបញ្ជាក់ជូនយើងខ្ញុំ។ ខ្ញុំ យើងខ្ញុំក៏មិនបានស្នើសុំបញ្ចូលជាភ័ស្តុតាងដែរ។ ដូច្នេះ ខ្ញុំគិតថាឯកសារនេះមិនទាន់ត្រូវបានអង្គជំនុំជម្រះទទួលយកជាភ័ស្តុតាងនៅឡើយទេ។ សូមខាងមេធាវីការពារក្ដីជួយបំភ្លឺពាក់ព័ន្ធនឹងការសុំទទួលយកឯកសារនេះផង។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ តាមរយៈការចងចាំរបស់ខ្ញុំ គឺថាឯកសារហ្នឹងវាស្ថិតនៅក្នុងឯកសារដែលយើងបានស្នើសុំដាក់ជាភ័ស្តុតាងគឺនៅចុងឆ្នាំមុន។ ហើយខ្ញុំគិតថាអង្គជំនុំជម្រះបានសម្រេចទទួលទទួលយកជាភ័ស្តុតាងរួចទៅហើយពេលនោះ ព្រោះថាមិនមានអ្នកណាជំទាស់ទៅនឹងការសុំដាក់ឯកសារនោះទេ។ ខ្ញុំ<មិនដឹងថាតើនោះជាការសម្រេចឬយ៉ាងណានោះទេ ហើយខ្ញុំមិនចាំច្រើនជាងហ្នឹងទៀតទេ> ប្រហែលជាមានការសម្រេច<>ជាផ្ទាល់មាត់ពេលនុ៎ង <ប៉ុន្តែក្នុងករណីណាក៏ដោយ ខ្ញុំដឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថា គឺក្រុម ខៀវ សំផន ដែលបានស្នើសុំដាក់ឯកសារទាំងអស់នេះជាភស្តុតាង ហើយការ>ស្នើសុំនោះ <ត្រូវបានទទួលយក>។

[១០:៥១:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥២:៣៥]

**កញ្ញា អង់តា ហ្គីសសេះ**

ដើម្បីជួយដល់អង្គជំនុំជម្រះ ខ្ញុំបានរកឃើញលេខនៃសំណើហើយ គឺថ្ងៃសម្រេច គឺថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦។ កំណត់ហេតុសវនាការនោះគឺ <E1/370.1> គឺនៅម៉ោង០៩:១២នាទី គឺអង្គជំនុំជម្រះបានសម្រេចទទួលយកឯកសារនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងច្បាស់លាស់ហើយ ហើយមានមូលដ្ឋានច្បាស់លាស់ហើយ អាចយកមកសួរដេញដោលបាន។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ អានបន្តសំណួរដេញដោលរបស់លោកចំពោះសាក្សីនេះតទៅទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរសំណួរខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកដឹងថាមានការបញ្ជាចេញពី សុន សេន ទៅកងពល១៦៤ បង្គាប់ឲ្យកម្មាភិបាលទាំងអស់ហ្នឹង កុំឲ្យប៉ះពាល់ដល់ជនភៀសខ្លួនវៀតណាម បើសិនណាជាគេឆ្លងកាត់ដែនទឹកគឺមិនត្រូវចាប់ពួកគេទេ អនុញ្ញាតឲ្យពួកគេបន្តដំណើរទៅគោលដៅរបស់ពួកគេចុះ? លោកនៅចាំថាមានការបញ្ជាបែបនេះទេ?

[១០:៥៤:០៤]

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** តាមសាក្សីដែលបានបញ្ជាក់ក្នុងរឿងនេះ អាហ្នឹងជាការពិត ខ្លួនខ្ញុំជាកម្មាភិបាលដែលនៅទទួលប្រធាននាវា ខ្ញុំមិនមានភារកិច្ចអីទៅរៀបចំរបៀបរៀបរយនៃការធ្វើដំណើរចេញចូលរបស់ជនបរទេសទាំងឡាយណាដែលឆ្លងកាត់ក្នុងអធិបតេយ្យនោះទេ ព្រោះខ្ញុំមានកាតព្វកិច្ចតែនៅក្នុងការហាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្វឹកហ្វឺន។ ដូច្នេះការបទបញ្ជាអីទាំងអស់ណា វានឹងមានអ្នកផ្សេងគេទទួលនៅក្នុងចំណុចឈរជើងរបស់កោះនីមួយៗ។ នេះអាចនឹងមានយ៉ាងនេះ។ បើសម្រាប់ខ្លួនខ្ញុំគឺអត់មានបានទទួលបទបញ្ជានេះទេ។

**ស៖** សូមអរគុណលោកសាក្សី។ តើត្រឹមត្រូវដែរឬទេថា នៅពេលដែលគេរកឃើញថាប្រជាជននៅលើទូក គឺជាកងទ័ពវៀតណាម តើត្រូវចាប់ខ្លួនពួកគេ ឬយ៉ាងណា?

**ឆ៖** តាមឯកសាររបស់ខ្ញុំបញ្ជាក់ គឺខ្ញុំមានចុះនៅក្នុងឯកសារនោះ។ មានថ្ងៃមួយ ខ្ញុំមិនចាំថ្ងៃថាតើថ្ងៃណា ហើយសូម្បីតែឆ្នាំមកដល់ថ្ងៃនេះ ខ្ញុំក៏មិនបានកំណត់ថាឆ្នាំណាដែរ។ តែខ្ញុំគិតថា ក្នុងពេលដែលខ្ញុំមានការហ្វឹកហ្វឺននាវាចរទៅតំបន់កោះ ដូចជាពូលូវៃចាស់ ពូលូវៃថ្មី ហើយនិងកោះតាង ខ្ញុំបានជួបជនជាតិវៀតណាមមួយនាក់ និងជនជាតិក្លឹងមួយនាក់នៅលើផែកោះតាង – កោះតាង។ តែខ្ញុំមិនបានសួរថាគេជានរណាទេ ខ្ញុំគ្រាន់តែសួរថា យុទ្ធជននៅលើផែនោះសួរថា គេជាជនជាតិអ្វី? គេមកពីណាទៅណា? ហើយយុទ្ធជនដែលនៅៗផែនោះ ក៏បានឆ្លើយប្រាប់ខ្ញុំថា គេជាជនជាតិវៀតណាមឆ្លងកាត់តំបន់ដែនទឹកនៅកោះអាគ្នេយ៍ខាងកើតកោះតាង។ ហើយពួកគេបានចាប់គេទាំងពីរនាក់នេះមកដល់យប់មិញ។ ហើយខ្ញុំក៏មានភារកិច្ចរបស់ខ្ញុំគឺថា មានការរៀបចំហាត់ហ្វឹកហ្វឺនកងទ័ពរបស់ខ្ញុំក្រោមកិច្ចបញ្ជារបស់ខ្ញុំផ្ទាល់ ខ្ញុំបន្តការងាររបស់ខ្ញុំ ដោយគ្រាន់តែទទួលព័ត៌មានដឹងៗដោយសង្ខេបខ្លី អត់មានថា ជ្រៀតជ្រែកការងារ ឬក៏ថា អ្វីដែលខ្ញុំត្រូវតាមដាននិងសង្កេតទេ។

[១០:៥៧:២៧]

**ស៖** ខ្ញុំយល់ហើយ ខ្ញុំសូមចូលបន្តទៅបញ្ហាពាក់ព័ន្ធទៅនឹងបញ្ហានេះជិតដិតតែម្តង។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក <គេបានសួរ>លោក<>អំពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅរបស់កម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំនឹងត្រឡប់មកសួរចំណុចនេះនៅពេលបន្តិចទៀតនេះ។ ឥឡូវសូមអានសម្រង់មួយផ្សេងទៀតចេញពីមេបញ្ជាការ <[redacted]> ចេញពីកំណត់ហេតុរបស់មេបញ្ជាការ <[redacted]> គឺឯកសារ E319/23.3.12។ នៅត្រង់សំណួរចម្លើយលេខ៧០ គាត់បានឆ្លើយដូចតទៅ៖ "សួរ៖ លោកបានឆ្លើយថាមានខ្មាំងពីរប្រភេទ ខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ។ តើលោកគិតឃើញថាអ្នកនេសាទវៀតណាមត្រូវបានចាត់ទុកថាជាខ្មាំងផ្ទៃក្រៅ ឬក៏យ៉ាងណា? ហើយត្រូវចាប់សម្លាប់ចោល ឬក៏យ៉ាងណា? ឆ្លើយ៖ ថាខ្ញុំមិនគិតអីចឹងទេ។ ខ្មាំងផ្ទៃខាងក្រៅនេះ គឺនិយាយអំពីកងទ័ពវៀតណាមនៅតាមព្រំដែន។ និយាយពី<ការចាប់រឹបអូស>ទូកវៀតណាម បើ<តាមខ្ញុំដឹង> ពួកនេសាទវៀតណាមមិនត្រូវបានចាត់ទុកថាជាខ្មាំងផ្ទៃក្រៅទេ។ ប៉ុន្តែ<>គេ<បាន>រំលោភដែន<ទឹកកម្ពុជាប្រជាធិបតេយ្យ>។"

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<លោកសាក្សី> តើពិតទេដែល [redacted] បាននិយាយថា <អ្នកនេសាទ និងអ្នកដែលជា>ជនភៀសខ្លួនមិនត្រូវចាត់ទុកថាខ្មាំងផ្ទៃក្រៅទេ ប៉ុន្តែខ្មាំងផ្ទៃក្រៅនេះ គឺនិយាយសំដៅទៅលើកងទ័ពវៀតណាមទៅវិញនោះទេ? តើលោកនៅចាំទេ?

[១០:៥៩:២៣]

**ឆ៖** បាទ សម្តីរបស់ [redacted] បានចុះនៅក្នុងឯកសារនេះ វាជាការពិតណាស់ ព្រោះព្រំដែនកម្ពុជា-វៀតណាម ពេលនោះវាជាការប្រយុទ្ធតឹងតែងតាំងពី៧៥ រហូតដល់ឆ្នាំ១៩៧៧។ ហើយដោយឡែក [redacted] បាននិយាយថា ជនជាតិវៀតណាមឆ្លងកាត់នៅតាមឆ្នេរនៅតាមដែនសមុទ្ររបស់កម្ពុជាជាជនភៀសខ្លួន នេះវាជាការត្រឹមត្រូវ ព្រោះជនជាតិភៀសខ្លួនមិនមែនជាសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យទេ។ សត្រូវរបស់កម្ពុជាប្រជាធិបតេយ្យពេលនោះ កំណត់យកពីរមុខសញ្ញាច្បាស់ គឺថាមួយខ្មាំងខាងក្រៅ ចំពោះកងទ័ពវៀតណាមដែលវាយទន្ទ្រានកាន់កាប់អធិបតេយ្យភាពកម្ពុជាដែនគោក និងដែនកោះរបស់កម្ពុជា។ ហើយខ្មាំងខាងក្នុង គឺជាភ្នាក់ងារដែលធ្វើឱ្យកម្ពុជាប្រជាធិបតេយ្យមានទំនាស់ផ្ទៃក្នុងផ្នែកកម្មាភិបាលមួយចំនួន ដែលចេះតែបង្កលក្ខណៈធ្វើឱ្យកម្ពុជាមានការគិតគូរដល់សភាពការណ៍គ្រប់បែបយ៉ាងនៅក្នុងផ្ទៃក្នុង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនឹងនិយាយអំពីខ្មាំងផ្ទៃក្នុងបន្តិចទៀតនេះ។ ខ្ញុំសូមអានសម្រង់ខ្លីមួយ ពីសាក្សីម្នាក់ផ្សេងទៀត និយាយអំពីកាលប្រវត្តិនៃឆ្នាំនីមួយៗ។ លោកប្រធាន នេះគឺសក្ខីកម្មរបស់<មេបញ្ជាការរង>កងពលលេខ១ ភូមិភាគបស្ចិម។ គាត់<អាច>នឹងចូលខ្លួនមកបង្ហាញសក្ខីកម្ម <ដូច្នេះហើយ>ខ្ញុំមិនបញ្ជាក់ឈ្មោះគាត់<ទេ> គឺឯកសារ E319/23.3.21 នៅក្នុងសំណួរចម្លើយ២៤។ លោកសាក្សី សាក្សីរូបនេះដែលគាត់ជាមេបញ្ជាការកងពលលេខ១ ភូមិភាគបស្ចិម គាត់បាននិយាយថា សូមដកស្រង់៖ “ក្នុងអំឡុង (សុំទោស) ពីឆ្នាំ១៩៧៥ ដល់៧៦ ការណែនាំនេះ គឺជាការណែនាំទូទៅ។ ពួកគេបានបង្គាប់ឱ្យយើងថា មិនត្រូវធ្វើអីប៉ះពាល់ដល់វៀតណាម ពីព្រោះប្រទេសយើងតូចណាស់ ហើយប្រទេសវៀតណាមជាប្រទេសមួយធំ។” បញ្ចប់ការដកស្រង់។ ត្រឹមត្រូវដែរទេ លោកដែលសាក្សីរូបនេះបាននិយាយថា ការបង្គាប់ណែនាំ គឺថាកុំបង្កបញ្ហារឿងរ៉ាវអីជាមួយវៀតណាម ពីឆ្នាំ១៩៧៥-៧៦ ព្រោះប្រទេសយើងតូច ប្រទេសគេធំ?

[១១:០២:៤២]

**ឆ៖** តាមសាក្សីរូបនេះបញ្ជាក់ នេះវាជាចម្លើយរបស់សាមីខ្លួនខាងគាត់។ សម្រាប់ខ្លួនខ្ញុំក៏យល់

ស្របថា ប្រទេសតូចមិនមានលទ្ធភាពអីទៅគំរាមកំហែង និងមានមហិច្ឆតាណាមួយទៅវាយយកប្រទេសធំបាននោះទេ។ អ៊ីចឹងជាទស្សនៈរបស់ខ្ញុំ ក៏យល់ស្របនឹងសម្ដីរបស់គាត់លើកឡើងដែរ។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរមួយទៀត ទាក់ទងទៅនឹងទាហានវៀតណាម ឬក៏កងទ័ពវៀតណាម ដែលបានបំពានព្រំដែន <ហើយត្រូវបានចាប់ខ្លួន>។ ក្នុងកំណត់ហេតុរបស់លោកហើយនិងនៅក្នុង<ចម្លើយដែលលោកឆ្លើយជាមួយ>មជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា អ្នកទាំងអស់នោះកាលណាគេចាប់បាន គេបញ្ជូនមកពីទីក្រុងភ្នំពេញ <ដើម្បីសួរចម្លើយ>។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** នេះជាក្នុងឯកសាររបស់ខ្ញុំ បញ្ជាក់នៅក្នុងនេះ គឺជាការត្រឹមត្រូវ ព្រោះខ្ញុំ ពាក្យដែលខ្ញុំនិយាយចូលនៅក្នុងឯកសារនេះ គឺជាសភាពការណ៍ប្រព័ន្ធទាក់ទងតាមតេអូ ឬយើង – តេអូ ហ្នឹងគឺយើងប្រើមានពីរ។ មួយ តាមរលកធាតុអាកាស។ ពីរ យើងប្រើតាមប្រព័ន្ធទូរស័ព្ទខ្សែ។ នេះជាការទទួលដឹងជាព័ត៌មាន តែជាក់លាក់របស់ខ្ញុំឃើញថា គេបញ្ជូនយ៉ាងម៉េច គេនាំយ៉ាងម៉េច អាហ្នឹងខ្លួនខ្ញុំអត់បានជួបប្រទះ ហើយឃើញហេតុការណ៍ទេ។

**ស៖** តើនៅពេលនោះ លោកបានដឹងដែរឬទេ គេបញ្ជូនទៅ ស-២១ ឬក៏ឮក្រោយឆ្នាំ១៩៧៩ទេ អំពី ស-២១នេះ?

[១១:០៤:៥៨]

**ឆ៖** សម្រាប់ខ្លួនខ្ញុំនៅមន្ទីរស-២១នេះ គឺខ្ញុំគ្រាន់តែដឹងថាវាជាសភាពការណ៍សម្រាប់អបរំអ្នកដែលមានពាក់ព័ន្ធលើការរស់នៅគ្រប់បែបយ៉ាងដែលមិនសមស្របនឹងសីលធម៌ ចរិតលក្ខណៈបុគ្គលិកជាមនុស្ស មានលក្ខណៈគេហៅថាមនុស្សយល់ការ។ អាហ្នឹងគឺគ្រាន់តែដឹងថាកន្លែងមន្ទីរនេះជាមន្ទីរអប់រំសម្រាប់កសាងកម្មាភិបាល ឬជាកន្លែងសម្រាប់ដោះស្រាយវិបត្តិផ្សេងៗនៅក្នុងអង្គភាពដែលមានការពាក់ព័ន្ធ។

**ស៖** ខ្ញុំមានសំណួរច្រើនទៀត ប៉ុន្តែខ្ញុំ ពេលវេលាខ្លីខ្ញុំទៅមុនទៀត។ លោកសាក្សីនៅក្នុងសក្ខីកម្មរបស់លោកទៅអ្នកស៊ើបអង្កេតដែលខ្ញុំបានបញ្ជាក់ខាងដើមនេះ លោកបាននិយាយទៅដល់ក្រុមខ្មាំងពីរ គឺខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ។ តើត្រឹមត្រូវដែរឬទេ គឺខ្មាំងទី១របស់កម្ពុជាប្រជាធិបតេយ្យ គឺវៀត-ណាម ហើយខ្មាំងទី២ គឺជាខ្មាំងផ្ទៃក្នុង? តើត្រឹមត្រូវដូចដែលលោកថាអ៊ីចឹងទេ?

**ឆ៖** នេះជាឯកសារបញ្ជាក់ នេះជាការត្រឹមត្រូវរបស់ខ្ញុំបានលើកឡើងនៅពេលនោះ។

**សៈ** នៅក្នុងចម្លើយដដែលនោះ គឺថាចម្លើយ៧៥នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ លោកបាននិយាយសំដៅទៅដល់វគ្គសិក្សា<> ឬក៏វគ្គអប់រំ<>ដែលរៀបចំឡើងដោយអគ្គសេនាធិការ នៅក្នុងទីក្រុងភ្នំពេញដែល សុន សេន ជាគណៈអធិបតីនៅកាលនោះ។ តើលោកនៅចាំអ្វីខ្លះអំពីវគ្គសិក្សាអប់រំ<ទាំង>នោះ ដែលលោក សុន សេន ធ្វើជាគណៈអធិបតី? តើគាត់បាននិយាយពីអ្វីខ្លះទាក់ទងទៅនឹងខ្មាំងខាងក្រៅ វៀតណាម ហើយនិងខ្មាំងផ្ទៃក្នុងនោះ?

[១១:០៧:២៨]

**ឆៈ** តាមខ្ញុំចាំ និយាយដោយខ្លីនៅពេលនោះ គឺគោលនយោបាយបញ្ជាក់អំពីសភាពការណ៍គាត់លើកពីអធិបតេយ្យភាពរបស់ព្រំដែនកម្ពុជាពេលនោះ គឺថានៅតាមព្រំដែនមិនមានភាពឯករាជ្យសន្តិសុខអីទេ វាជាសភាពការណ៍ប្រយុទ្ធប៉េះប៉ោះជាប់រៀងរាល់មុខសញ្ញានៃសមរភូមិជាប់ព្រំដែនកម្ពុជា-វៀតណាម ហ្នឹងទី១។ អ៊ីចឹងគោលនយោបាយពេលនោះ បានលើកបញ្ជាក់ថាខ្មាំងដែលប្រឈមនឹងកម្ពុជាប្រជាធិបតេយ្យគឺមានពីរ គឺខ្មាំងវៀតណាម និងខ្មាំងផ្ទៃក្នុង។ នេះជាការត្រឹមត្រូវ។

**សៈ** ខ្ញុំសួរសំណួរជាក់ស្តែងវិញ។ បុគ្គលដែលនៅទី២ <គឺ>មេបញ្ជាការឈ្មោះ ឌឹម <នៃ>កងពល១៦៤ តើគាត់ជាខ្មាំងផ្ទៃក្នុងដែរឬទេ?

**ឆៈ** ឈ្មោះ ឌឹម តាមខ្ញុំស្គាល់គាត់ ខ្ញុំមិនមែនជាអ្នកសង្កេតថាតើជាខ្មាំងផ្ទៃក្នុង ឬយ៉ាងណាទេ។ តែឈ្មោះ ឌឹម ក្រោយពីរៀបចំកងពលហើយ គាត់ក្នុងឋានៈជាមេបញ្ជាការ ខ្ញុំបានជួបមុខគាត់ពីត្រឹម ៧៥ ចុង៧៥, ៧៦ពេញ និង៧៧បាត់ខ្លួន។ ដូច្នេះខ្ញុំ ខ្លួនខ្ញុំមិនកំណត់ថាគាត់ជាផ្ទៃក្នុង ឬមួយយ៉ាងណាអាហ្នឹងខ្ញុំអត់ជ្រាបទេ តែខ្ញុំគ្រាន់តែបញ្ជាក់ក្នុងឯកសារហ្នឹង ច្បាស់ថាគាត់បាត់ខ្លួន ខ្ញុំអត់បានឃើញ។

**សៈ** អរគុណលោកសាក្សី។ ឥឡូវនេះយើងពិនិត្យមើលដើម្បីរំឭកការចងចាំរបស់លោកទាក់ទងទៅនឹងភ័ស្តុតាងជាក់ស្តែង ដែលនិយាយអំពីថាអ្នកណាជាខ្មាំងផ្ទៃក្នុង អ្នកណាជាខ្មាំងខាងក្រៅ។ ខ្ញុំអាចសេចក្តីដកស្រង់ជូនលោកម្តងទៀត អំពីមេបញ្ជាការអនុសេនាធំមួយ<នៃកងពល១៦៤> ឈ្មោះ [redacted] សំណួរ និងចម្លើយ៤៩។ ខ្ញុំនឹងសួរ<ពីប្រតិកម្មរបស់លោក> ទាក់ទងទៅនឹងអ្វីដែលគាត់ឆ្លើយទៅអ្នកស៊ើបអង្កេត៖ “សំណួរ៖ អនុលោមតាមឯកសារ “ទង់បដិវត្ត” <ឬ “យុវជន យុវនារីបដិវត្ត”> គឺថាគោលបំណងសំខាន់ពីររបស់កម្ពុជាប្រជាធិបតេយ្យ គឺវាយប្រហារខ្មាំងផ្ទៃក្នុង ហើយនិងវាយប្រហារខ្មាំងខាងក្រៅ។ សូមលោកបំភ្លឺបញ្ហានេះ?” ពេលនោះគាត់ឆ្លើយដូចក្រោមនេះ ខ្ញុំសូមដកស្រង់៖ “ខ្មាំងផ្ទៃក្នុង គឺនិយាយអំពីដែលអ្នកបង្កប់នៅក្នុងជួរបក្ស។ យើងនិយាយអំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា អំពីការ

បង្កើតបក្សពលករកម្ពុជា ដែលដឹកនាំដោយ សឺង ង៉ុកមិញ ហើយកុមារខ្មែររាប់រយនាក់ដែលបញ្ជូនទៅ<រៀននៅ>វៀតណាម ហើយគេបញ្ជូនត្រឡប់មកវិញ។ ខ្មាំងផ្ទៃក្នុងក៏មានន័យថា យើងត្រូវតស៊ូ<ផ្អែកមនោគមន៍វិជ្ជា> ដើម្បីបង្កើតវណ្ណៈអធន ហើយនិងវាយប្រហារវណ្ណៈអ្នកមាន ហើយផ្អែកលើវណ្ណៈក្រីក្រ។ ហើយខ្មាំងខាងក្រៅ គឺសំដៅដល់វៀតណាម គឺយុទ្ធសាស្ត្ររបស់<វៀតណាមតាំងពី>សម័យហូជីមិញ ដែលមានគោលបំណង បង្កើត<សហ>សម្ព័ន្ធឥណ្ឌូចិនដែលដាក់បញ្ចូលនូវប្រទេសបី មានវៀត-ណាម ឡាវ និងកម្ពុជា នៅក្រោមការគ្រប់គ្រងរបស់វៀតណាម។" សូមបញ្ចប់សេចក្ដីដកស្រង់។ លោកសាក្សី តើព័ត៌មានទាំងអស់នេះ ដែលខ្ញុំអាននេះ លោកបានស្ដាប់ឮផងដែរពីលោក សុន សេន ដែលថាគាត់និយាយនៅក្នុងវគ្គសិក្សា<មួយនៃវគ្គសិក្សាទាំងអស់>ហ្នឹង <ឬក៏លោកអាចអាននៅក្នុងទស្សនាវដ្ដីទង់បដិវត្ត> ឬក៏លោក<បានឮក្នុងលក្ខណៈផ្សេងទៀត? តើលោកធ្លាប់ឮប្រហាក់ប្រហែលនឹងទេ>?

[១១:១២:០៦]

**ឆ៖** តាមខ្លឹមសារសម្ដីរបស់សាក្សី [redacted] នេះជាកំណត់ហេតុដែលគាត់បានស្រង់ចេញពីខ្លួនគាត់។ ហើយព័ត៌មាននេះ ឬថាគោលនយោបាយនេះ វាជាគោលនយោបាយមួយដែលពេលនោះ គឺបក្សកុម្មុយនីស្ដកម្ពុជាបានលើកអំពីកសាងគោលជំហររបស់បក្សមួយរូបៗ ទៅជាបក្សវណ្ណៈអធនដើម្បីក៏សម្រេចកសាងនូវប្រទេសជាតិមួយឲ្យមានភាព គេហៅថា កសិករក្រីក្រ និងវណ្ណៈក្រីក្រជាអ្នកកាន់អំណាចនៅក្នុងសម័យឆ្នាំនោះ។ ដូច្នេះអ្វីដែល [redacted] គាត់លើក អាហ្នឹងវាជាការត្រឹមត្រូវ វាជាគោលនយោបាយ វាជាមាគ៌ារបស់គាត់ ដែលគាត់យល់ខ្លួនគាត់។

**ស៖** ដូច្នេះអ្វីដែលគាត់និយាយក្នុងកំណត់ហេតុអំមិញនេះគឺថា គឺជាអ្វីដែលលោកបានឮផងដែរ។ <លោកចាំថាបានឮបញ្ហា>ទាក់ទងទៅនឹងបក្សពលករ<កម្ពុជា ឬ>បក្ស<ការងារ>កម្ពុជា ហើយនិងអំពី<>សហព័ន្ធឥណ្ឌូចិនអីជាដើមនោះ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** នេះជាការត្រឹមត្រូវ ព្រោះក្រោយពីហ្សឺណែវ ឆ្នាំ១៩៤០ -- អ៊ី១៩៥៤មក គឺហូជីមិញមានផែនការចងប្រទេសបីជាប់គ្នា គឺកម្ពុជា វៀតណាម ទៅជា – លាវ ទៅជាសហព័ន្ធឥណ្ឌូចិន ដោយមានហូជីមិញជាអ្នកគ្រប់គ្រងអំណាចនៅឥណ្ឌូចិន។ នេះជាការត្រឹមត្រូវ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត អំពី<សហការីម្នាក់ទៀតនៅក្នុង>កងពល<> បាទដែលគាត់បានឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ គាត់ឈ្មោះ <ណាំ ឡួន> គឺថាឯកសារ E319/23.3.17.1 បកប្រែទៅជាភាសាទាំងបី គឺថា ERN <ជា

ភាសាអង់គ្លេស> 01170833, បារាំង <00996698>, ខ្មែរ 00955619។--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១១:១៥:១៨]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។ យើងមិនបានរកឃើញឯកសារហ្នឹងនៅក្នុងបញ្ជីឯកសារដែលអង្គជំនុំជម្រះទទួលយក <តាម>វិធាន៨៧(៤)ទេ គឺឯកសារ E319/23.3.17.1 នេះ <ដូចជាឯកសារទាំងអស់ពាក់ព័ន្ធទៅនឹងសាក្សីនេះ>។ យើងគិតថាឯកសារនេះមិនត្រូវបានស្នើ ហើយអង្គជំនុំជម្រះក៏មិនទាន់ទទួលយកឯកសារនេះដែរ។ ដូច្នេះសូមឲ្យមានការ ពិនិត្យផ្ទៀងផ្ទាត់ទៅលើឯកសារនេះ។ បើមិនមានការទទួលយកដោយអង្គជំនុំជម្រះទេ គឺមិនអាចប្រើប្រាស់ឯកសារនេះបានទេ<នៅថ្ងៃនេះ រហូតទាល់តែមេធាវីការពារក្ដីស្នើសុំដាក់ឯកសារនេះជាផ្លូវការ ហើយភាគីទាំងអស់អាចនិយាយពាក់ព័ន្ធចំពោះរឿងការប្រើប្រាស់>ឯកសារនេះ។ សូមអរគុណ។

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដថា ម៉េចជាការព្រួយបារម្ភរបស់សហមេធាវីនាំមុខ។ អ៊ីចឹងលោកប្រធាន គឺថាមានការកែប្រែនឹងកាលបរិច្ឆេទ យើង<មិនបាន>ដាក់<ឯកសារនេះ>នៅក្នុង*អ៊ីនធីហ្វេស* <គឺអាចអ៊ីចឹង។ ខ្ញុំទើបតែទទួលបានសារមួយ។ ដូច្នេះ> ទោះជាយ៉ាងណាក្ដី <តាមរយៈសំណើនេះ>គឺថាខ្ញុំសុំអានអំពីសេចក្ដីដកស្រង់មួយ ឬពីរចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១១:១៦:៣០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកបានគោរពតាមវិធាន៨៧(៤)ដែរឬទេ? តើលោកបានស្នើសុំ ហើយអង្គជំនុំជម្រះបានអនុញ្ញាតដែរឬទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ឯកសារនេះគឺមាននៅក្នុង*អ៊ីនធីហ្វេស* ក៏ប៉ុន្តែតាមការយើងយល់គឺមិនមានធ្វើសំណើសុំតាមរយៈវិធាន៨៧(៤)នោះទេ។ <ដូច្នេះហើយទើបយើងស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យមើលនៅថ្ងៃនេះ។>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

<តើខ្ញុំអាចធ្វើសំណើ>ដោយផ្ទាល់មាត់ទៅអង្គជំនុំជម្រះនៅពេលនេះ<បានទេ ដើម្បីឱ្យ> ទទួលស្គាល់ឯកសារនេះ<>?

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៧:៣៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំឱ្យលោកបំភ្លឺ <មុនពេល>លោកស្នើផ្ទាល់មាត់<នៅពេលឥឡូវនេះ> តើលោកបានស្នើជាលាយលក្ខណ៍អក្សរពីមុនដែរឬទេ? យើងជៀសវាងក្នុងការមានសេចក្ដីសម្រេចពីរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ទេ យើងខ្ញុំមិនបានស្នើជាលាយលក្ខណ៍អក្សរពីមុនទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៨:១២]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅខាងភាគីផ្សេងទៀត សហមេធាវី -- សហតំណាងសហព្រះរាជអាជ្ញា លើការសំណើដាក់ទទួលយកឯកសារ E319/23.3.17.1 របស់សហមេធាវីការពារក្ដី ខៀវ សំផន ដើម្បីដាក់ពិភាក្សាដេញដោលសាក្សីរូបនេះ? មានមតិជំទាស់យ៉ាងម៉េចដែរ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ តាមទស្សនៈរបស់យើង គឺយើងមានវិធានដែលត្រូវគោរព។ យើងត្រូវតែគោរពគោលការណ៍ចំពោះមុខនៅចំពោះអង្គជំនុំជម្រះនេះ។ ប្រសិនបើភាគីមកក្នុងសវនាការដោយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន គឺមិនគោរពទៅតាមនីតិវិធីដែលបានកំណត់តាមរយៈវិធាន៨៧(៤)នោះ។ ហើយបើខ្លួនមកៗស្នើភ្លាមៗអ៊ីចឹង វាដូចជាមិនសមរម្យទេ។ វាក្លាយទៅជាទម្លាប់អាក្រក់មួយ។ ដូច្នេះសុំឱ្យគោរពភាគីផ្សេងទៀតផង ហើយគោរពអង្គជំនុំជម្រះផង។ ហើយអង្គជំនុំជម្រះក៏មិនអាចសម្រេចភ្លាមៗបានដូច្នេះដែរ។ ខ្ញុំគិតថា ដូចជាយឺតពេលណាស់ទៅហើយ។ យើងគួរតែធ្វើដូចទម្លាប់ទៅ។ យើងៗបានព្យាយាមណាស់ គោរពទៅតាមអ្វីដែលកត់ដោយអង្គជំនុំជម្រះ គឺយើងប្រើប្រាស់ឯកសារហ្នឹង សុទ្ធតែឯកសារដែលយើងដាក់ជូនអង្គជំនុំជម្រះសម្រេចជាមុន ហើយអង្គជំនុំជម្រះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏សម្រេចទទួលឯកសាររបស់យើង។ អ៊ីចឹងភាគីផ្សេងទៀត ក៏គួរតែធ្វើដូចគ្នាអ៊ីចឹងដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន--

[១១:១៩:៤៩]

**ប្រធានអង្គជំនុំ៖**

ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ជាទូទៅនោះ គឺយើងមិនជំទាស់ទៅនឹងការប្រើប្រាស់ឯកសារ<ដោយ>មេធាវីការពារក្តីទេ។ យើងយល់ច្បាស់អំពីសង្វាក់ការងាររបស់ភាគីនីមួយៗ ក៏ប៉ុន្តែយើងត្រូវតែគោរពច្បាប់ ទាំងមេធាវីការក្តីលោក ខៀវ សំផន ផង ត្រូវតែស្នើសុំមុន មិនត្រូវមកស្នើសុំភ្លាមៗនៅក្នុងសវនាការទាន់ហន់បែបហ្នឹងទេ ត្រូវតែគោរពទៅតាមវិធាន៨៧(៤)។ នេះជាវិធីសាស្ត្រដែលយើងត្រូវគោរព វាត្រូវផ្តល់ពេលវេលាឲ្យភាគីដើម្បីពិនិត្យមើលឯកសារ ពិនិត្យមើលបញ្ជី។ អ៊ីចឹងសូមឲ្យមានការគោរពចំពោះភាគីបន្តិចផង។ សូមស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះជាមុនផង បើអ៊ីចឹងទេ អ៊ីចឹងបង្កើត*អ៊ុនធីហ្វេស*ហ្នឹងមកធ្វើអី ហើយបង្កើតវិធានផ្ទៃក្នុងហ្នឹងមកធ្វើអី បើភាគីប្រើឯកសារបានតាមចិត្តដោយមិនចាំបាច់ប្រាប់ភាគីផ្សេងទៀតនោះ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គឺ<យើងខ្ញុំនឹង>គោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

ចុះភាគីមេធាវីការពារក្តី ខៀវ សំផន មានមតិយោបល់កត់សម្គាល់អ្វីដែរទេ លើសំណើសុំរបស់មេធាវី វ៉ិចទ័រ កូប៉េ មេធាវីការពារក្តី នួន ជា លើការសំណើសុំដាក់ឲ្យអង្គជំនុំជម្រះទទួលយកឯកសារអម្បាញ់មិញនេះ នាពេលនេះ?

[១១:២១:១៣]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនមានយោបល់អ្វីជាក់លាក់ទេ លោកប្រធាន ពីព្រោះថាមេធាវី កូប៉េ គាត់ចង់ប្រើឯកសារដែលខ្លួនគិតថាវាមានព័ត៌មានដោះបន្ទុក។ ដូច្នេះខ្ញុំមិនមានយោបល់អីពិសេសទេ<ក្នុងអំឡុងពេលដែលបានផ្តល់ឲ្យភាគីនិយាយពីបញ្ហានេះ>។ ខ្ញុំគ្រាន់តែរំឭកថា ជួនកាលទៅវាមានបញ្ហា ដោយសារតែយើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិន<មានពេលវេលាចូលរួមឲ្យបានគ្រប់គ្រាន់ ហើយមិន>អាចគិតទុកជាមុនបាននូវការសួរសំណួររបស់យើងជាមុនបាន <ហើយមានបញ្ហាជាច្រើនត្រូវបានទុកមួយឡែកសិន>។ <ខ្ញុំបានស្តាប់ការសង្កេតរបស់សហព្រះរាជអាជ្ញា។ បើខ្ញុំមិនច្រឡំទេ យើងបានឃើញជាច្រើនដងមកហើយនៅចំពោះមុខអង្គជំនុំជម្រះនេះ នូវឯកសារជាច្រើនដែលមិនត្រូវបានទទួលយកមកពិភាក្សា ហើយដែលមិនត្រូវបានស្នើសុំដាក់បញ្ចូលក្នុងសំណុំរឿង ហើយបញ្ហានេះក៏បានកើតឡើងចំពោះភាគីផ្សេងទៀតផងដែរ។ ខ្ញុំគ្រាន់តែសូមរំឭកពីបញ្ហានេះ។ ដូច្នេះយើងនៅក្នុងក្រុមការពារក្តី ខៀវ សំផន យើងដឹងច្បាស់ណាស់ពីអារម្មណ៍នៃការស្នើសុំប្រើប្រាស់ឯកសារទាំងអស់នេះ ពីសំណាក់សហភាគីរបស់យើងនៅថ្ងៃនេះ នៅក្នុងបរិបទមួយនៃការសួរសំណួរ ដែល>គាត់គិតថាវាជាការដោះបន្ទុក។ អ៊ីចឹងយើង ខ្ញុំគិតថាមិនជំទាស់អ្វីនឹងការប្រើប្រាស់ឯកសារនេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការស្នើសុំបំភ្លឺមួយពីមេធាវីការពារក្តីលោក នួន ជា។ ខ្ញុំកត់សម្គាល់ឃើញថាឯកសារនេះ គឺជាកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឌី.ស៊ី.ខេម។ តើមានឯកសារផ្សេងទៀតពាក់ព័ន្ធទៅនឹងសាក្សីដដែលនេះទេ? តើសហចៅក្រមស៊ើបអង្កេតមានបានស្តាប់ចម្លើយសាក្សីរូបនេះទេ? លោកមានឯកសារផ្សេងទៀតទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំជឿថាមានសម្ភាសពីរដងចំពោះសាក្សីរូបនេះ ទាក់ទងគឺឯកសារ E319/23.3.17 ហើយនិង E319/23.3.18។

[១១:២៣:២១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើកំណត់ហេតុទាំងពីរនេះត្រូវបានធ្វើសំណើសុំ ដើម្បីឲ្យអង្គជំនុំជម្រះទទួលយកយោងតាមវិធាន ៨៧(៤) ហើយឬនៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

អត់ទេ លោកចៅក្រម ឡាវែន៍ ចម្លើយគឺទេ។ បញ្ហានោះ នៅត្រង់ថាគឺជាខណៈពេលចុងក្រោយ

ដែលយើងធ្វើការអំពីវគ្គថ្មី ដែលថាមិនទាន់បានស៊ើបអង្កេតនៅក្នុងតាមដីកាដំណោះស្រាយនៅឡើយទេ។ តាមពិតយើងយល់ស្របថាយើងខ្ញុំយឺត ប៉ុន្តែយើងមិនមានចេតនាប៉ុនប៉ងថាក្នុងចេតនាអាក្រក់នោះទេ។ <យើងទើបតែរកឃើញឯកសារនេះនៅក្រោយកាលបរិច្ឆេទ១២ម៉ោង> ហើយយើង<និង>ដាក់សំណើ <តាមវិធាន៨៧ ប៉ុន្តែនៅពេលនេះ ដោយសារតែ>វាមានភាពពាក់ព័ន្ធ ហើយយើងខ្ញុំចង់ប្រើឯកសារនេះ <ដើម្បីសួរសាក្សីនេះ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ហើយដូច្នេះ>លោក<បាន>ដាក់នៅក្នុង*អ៊ីនធីហ្វេស* <ដែលជាការល្អ ព្រោះថាយ៉ាងហោចណាស់គេអាចកត់សម្គាល់បាន ប៉ុន្តែលោកមិនបានពិនិត្យមើលថាតើវាបានឆ្លងកាត់តាម> វិធាន៨៧(៤) <ឬទេ។ តើវាអ៊ីចឹងឬ? តើស្ថានភាពនេះឬ?>

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំយល់អ៊ីចឹង។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៦:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសំណើសុំចុងក្រោយក្នុងការដាក់បង្ហាញឯកសារពីសំណុំរឿងផ្សេង យកមកដាក់នាពេលនេះរបស់មេធាវី វ៉ិចទ័រ កូប៉េ ដែលស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារ E319/23.3.17.1នេះ នាពេលនេះ ដោយមូលហេតុគឺ លោកមេធាវីដាក់យឺតពេល ហើយលោកមេធាវីមិនបានគោរព និងអនុវត្តឱ្យបានម៉ឺងម៉ាត់តាមវិធាន បញ្ញត្តិវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទេ។ ហើយម្យ៉ាងទៀតគឺ លើកក្រោយ គឺឯកសារត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមវិធាននេះ ហើយក្នុងករណីចាំបាច់ គឺឯកសារទាំងអស់ដែលមានការពាក់ព័ន្ធក្នុងការផ្តល់សក្ខីកម្មត្រូវធ្វើសំណើជាមុន។ ហើយម្យ៉ាងទៀត ឯកសារនេះ តាមការពិនិត្យបឋមរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងឃើញថាមានចំនួនច្រើនទំព័រណាស់ អ៊ីចឹងគឺមិនអាចដោះស្រាយបញ្ហាហ្នឹងបានទេ។ ហើយសំអាងហេតុហ្នឹង អង្គជំនុំជម្រះនឹងបញ្ជាក់បន្ថែមនៅពេលក្រោយទៀត។

បាទ សូមអញ្ជើញលោកមេធាវី កូប៉េ បន្តតាំងសំណួរផ្សេងទៀត ដែលពាក់ព័ន្ធនឹងឯកសារផ្សេងទៀត ចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដូចជាមិនយល់ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទេ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<តើខ្ញុំអាចបន្ថែមបន្តិចបានទេ? ខ្ញុំដឹងថាលោកត្រូវការពេលវេលា ប៉ុន្តែការសម្រេចមួយនៅក្នុងការគ្រប់គ្រងរបស់លោកគឺថា ជាមូលដ្ឋានយើងត្រូវដោះស្រាយនូវរាល់ឯកសារពាក់ព័ន្ធទាំងអស់នៅពេលជាមួយគ្នា ហើយតាមអ្វីដែលខ្ញុំឮគឺវាមានដល់ទៅ>៦០ទំព័រឯណោះ <ដែលវាធ្វើឲ្យពិបាកក្នុងការសម្រេចភ្លាមៗដោយមិនបានព្រាងទុក>។

[១១:២៨:៤៤]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន គឺថាមេធាវីការពារក្ដី គ្រាន់តែសុំស្នើពេលបន្ថែមទៀតដើម្បីសួរសាក្សីរូបនេះ ហើយយើងស្ទើរតែដល់ម៉ោងដប់មួយកន្លះហើយ គឺថាយើងមានពីរវគ្គ ហើយខ្ញុំត្រូវពេលបន្ថែមទៀតដើម្បីសួរសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

លោកត្រូវការពេលវេលាប្រហែលប៉ុន្មានទៅ? ហើយគួរតែគិតគូរឲ្យបានច្បាស់លាស់សរុបរវាងលោក ជាមួយនឹងមេធាវី ខៀវ សំផន ក្នុងការសាកសួរសាក្សីរូបនេះ ដើម្បីអង្គជំនុំជម្រះសម្រេច។

**កញ្ញា អង់តា ហ្គីសសេ៖**

សម្រាប់មេធាវីការពារក្ដីលោក <ខៀវ សំផន> ខ្ញុំសូមឆ្លើយតបជូនលោកប្រធានថា ខ្ញុំត្រូវការពេលប្រហែលជាកន្លះម៉ោង ដើម្បីសួរសាក្សីរូបនេះ ពីព្រោះថា ប្រធានបទមួយចំនួនដែលយើងចង់សួរនោះ គឺត្រូវបានលោកមេធាវី កូប៉េ សួរស្ទើរតែអស់ទៅហើយ។ ដូច្នេះខ្ញុំមិនដឹងថាតើលោកមេធាវី កូប៉េ <ត្រូវការ>ពេលប៉ុន្មានទៀតទេ នៅចំពោះប្រធានបទដែលគាត់ចង់សួរតទៅទៀតនោះ។ <គាត់អាចជម្រាបជូនលោកចៅក្រមបាន។> ក៏ប៉ុន្តែ<វាពិតណាស់ថា បើសិនជាប្រធានបទដែលគាត់ចង់ពិភាក្សានោះនៅក្នុងរយៈពេលដែលបានផ្ដល់ឲ្យគាត់ -- បើសិនជាផ្ដល់ពេលឲ្យគាត់ នោះពេលសម្រាប់យើងខ្ញុំសួរដេញដោលសាក្សីនឹងត្រូវកាត់បន្ថយក្នុងរយៈពេលដូចគ្នា>។ ក៏ប៉ុន្តែក្នុងដំណាក់កាលនេះ យើងអាចប្រាប់បានថា យើងត្រូវការពេលប្រហែលជាកន្លះម៉ោង លោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជម្រាបតុលាការថា គឺថា បើសូមស្នើឲ្យតុលាការអនុញ្ញាតឲ្យខ្ញុំបានពេលមួយវគ្គពេញបន្តទៀត ដើម្បីខ្ញុំសួរសំណួរនេះ បាទ សាក្សីរូបនេះ។

[១១:៣០:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

សូមអរគុណលោកប្រធាន។ ជាគោលការណ៍ គឺយើងមិនជំទាស់ទៅនឹងការបន្ថែមពេលវេលាឲ្យមេធាវីការពារក្តីនោះទេ ដោយសារតែសាក្សីរូបនេះ គាត់មានព័ត៌មានច្រើនដែលត្រូវផ្តល់ជូន។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំក៏ស្នើសូមឲ្យមានការបន្ថែមពេលដល់ខាងយើងខ្ញុំផងដែរ ពីព្រោះថាយើងក៏មានប្រធានបទច្រើនដែលត្រូវសួរ ហើយយើងចង់ត្រឡប់មកសួរអំពីហេតុការណ៍ជាច្រើនពាក់ព័ន្ធនឹងសាក្សីរូបនេះ។ កាលពីម្សិលមិញ បើសិនជាមេធាវីការពារក្តីសួរឲ្យបានលឿន ពាក់ព័ន្ធទៅនឹងការវាយយកទីក្រុងភ្នំពេញនោះ ប្រហែលជាមិនត្រូវការពេលច្រើនទេ <ប៉ុន្តែនោះមិនមែនជាបញ្ហាសម្រាប់ពេលនេះទេ>។ ដូច្នេះយើងអត់មានជំទាស់ទេ គ្រាន់តែសុំឲ្យ បើផ្តល់ខាងមេធាវីការពារក្តី ក៏សូមផ្តល់ជូនខាងយើងផងដែរ នូវពេលវេលាបន្ថែមនោះ លោកប្រធាន។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៣:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបន្ថែមម៉ោងភាគីទាំងសងខាង មួយវគ្គនៃថ្ងៃសវនាការ សម្រាប់មួយភាគី សម្រាប់ក្រុមមេធាវីការពារក្តី គឺឲ្យមួយវគ្គទៀត គឺវគ្គទី១នៅរសៀលនេះ។ ហើយចំណែកឯភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺសរុបមានបីវគ្គនៃពេលវេលាសវនាការ។

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សី

មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៣]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីនួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំនៅសល់ពេលតែ៣០នាទីទៀតទេ ដែលត្រូវសួរលោក ដូច្នេះសូមលោកឆ្លើយសង្ខេប បើអាច<ធ្វើ>បាន<ក្នុងការឆ្លើយទៅនឹងសំណួររបស់ខ្ញុំ>។ មុនពេលឈប់សម្រាកពិសាបាយថ្ងៃត្រង់ ខ្ញុំព្យាយាមរំឭកការចងចាំរបស់លោកពាក់ព័ន្ធទៅនឹងអ្វីដែល សុន សេន អាចធ្លាប់បាននិយាយទៅកាន់កម្មាភិបាលកងពល១៦៤ <នៅក្នុង>វគ្គរៀនសូត្រ<ទាំងអស់នោះ>។ ខ្ញុំព្យាយាមប្រើប្រាស់ឯកសារមួយរបស់សហការីរបស់លោក អតីតយុទ្ធមិត្តរបស់លោកមកពីកងពល១៦៤។ <ប៉ុន្តែខ្ញុំនឹងប្រើប្រាស់ឯកសារមួយទៀតជំនួសវិញ ដើម្បីដឹងថាតើខ្ញុំអាច>ជួយរំឭកដល់ការចងចាំរបស់លោក<បានទេ ទាក់ទងទៅនឹង>អ្វីដែល សុន សេន អាចធ្លាប់បាននិយាយនោះ។ លោកប្រធាន

ឯកសារនេះគឺឯកសារ E3/13 នេះគឺជាកំណត់ហេតុនៃអង្គប្រជុំរបស់លេខា និងអនុលេខាកងពលនានា និងក៏ដូចជាកងវរសេនាធំឯករាជ្យ <គឺឯកសារ> ចុះថ្ងៃទី០៩ ខែតុលា ១៩៧៦។

[១៣:៣៤:៤៨]

លោកសាក្សីគឺថា ខ្ញុំជឿថាលោកមិនដែលបានចូលរួមក្នុងអង្គប្រជុំនេះ ពីព្រោះវាពាក់ព័ន្ធទៅនឹងការប្រជុំរបស់មេបញ្ជាការ និងអនុបញ្ជាការកងពល។ ប៉ុន្តែមេបញ្ជាការកងពល១៦៤ មាស មុត និងអនុបញ្ជាការ ឌឹម ក៏មានវត្តមានដែរ។ <អ៊ីចឹងហើយប្រហែលជា>លោក<អាចប្រាប់យើងបាន>អំពីទស្សនៈ <និងគោលជំហរ>របស់ សុន សេន នៅក្នុងអង្គប្រជុំនេះ។ ខ្ញុំសូមចាប់ផ្ដើម អង់គ្លេសគឺ 00940342, ខ្មែរ 0052406 *(ស៊ីក)*, បារាំង 00334975។ សុន សេន បាននិយាយនៅក្នុងអង្គប្រជុំនោះ មុនពេលអនុបញ្ជាការរបស់លោកឈ្មោះ ឌឹម បានឡើងនិយាយនៅក្នុងអង្គប្រជុំនោះ និង <ប្រតិកម្មទៅនឹង>អ្វីដែល ឌឹម បាននិយាយ ហើយ សុន សេន បាននិយាយ<>ដូចតទៅនេះ គាត់បានបែងចែកដាច់ពីគ្នារវាងខ្មាំងទាំងពីរប្រភេទ។ ទី១ គាត់និយាយអំពីខ្មាំងនៅបស្ចិម។ <គាត់និយាយពី> ខ្មាំងពីខាងលិចវាយកោះ<នានា> ជាពិសេសកោះតាង និងកោះពូលូវ៉ៃ ហើយទ័ពពួកក្បត់ហ្នឹងគឺឈ្មោះជាទ័ពរបស់ សឹង ង៉ុកថាញ់ <គឺ>បុគ្គលម្នាក់ដែលយើងបាននិយាយ<ដោយសង្ខេបកាល>ពីម្សិលមិញផងដែរ។ សំណួររបស់ខ្ញុំ គឺថាលោកសាក្សី តើលោកធ្លាប់ឮ សុន សេន និយាយស្រដៀងគ្នានេះនៅក្នុងអង្គប្រជុំ -- នៅក្នុងវគ្គរៀនសូត្រ<ទាំងអស់នោះទេ ថាមានខ្មាំងពីរប្រភេទ។> ទី១ គឺខ្មាំងខាងកើត និងខ្មាំងខាងលិច?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** ក្នុងរយៈពេលរៀនសូត្រជាមួយ សុន សេន នៅស្តាតអូឡាំពិក ទីក្រុងភ្នំពេញ ក្នុងឆ្នាំ៧៦ ពេលហ្នឹងគាត់បាននិយាយតែពីរឿងរៀបចំកងទ័ព ដើម្បីកាន់កាប់នៅចំណុចសំខាន់ៗរបស់អធិបតេយ្យភាពកម្ពុជា។ នៅខាងភូមិភាគឦសានមាន មណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង រហូតដល់ឆ្នេរសមុទ្រកម្ពុជា។ នេះជាគោលធំរបស់អគ្គមេបញ្ជាការ សុន សេន គាត់មានប្រសាសន៍ក្នុងពេលនោះ។ ហើយក្រោយមកទៀត គាត់បានបញ្ជាក់អំពីខ្មាំងដែលប្រឈមចំពោះកម្ពុជាប្រជាធិបតេយ្យ គឺមានពីរ។ ខ្មាំងទី១ គឺជាសត្រូវខាងក្រៅ។ ខ្មាំងទី២ គឺសត្រូវផ្ទៃក្នុង។ អ៊ីចឹងគាត់កំណត់ថា បើខាងក្រៅធ្វើសកម្មភាព ខាងក្នុងក៏មានផែនការបន្តការប្រកួតប្រជែងនៅក្នុងការប្រយុទ្ធដណ្ដើមយកប្រៀបខាងគេហៅថារបៀបជាចារកិច្ច ឬក៏ថាចារកម្មបង្កប់ និងបង្កបង្កើតជារឿងហេតុមួយនៅក្នុងកម្ពុជាទាំងមូល ទាំងអស់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៣៩:០៣]

**ស៖** ប៉ុន្តែតើលោកនៅចាំ គាត់និយាយអំពីខ្មាំងខាងក្រៅ<> គឺខ្មាំងខាងលិច និងមួយទៀត ខ្មាំងខាងកើត? តើមានការញែកដាច់ពីគ្នា ខ្មាំងផ្ទៃក្នុងនេះ ខ្មាំងផ្ទៃក្នុងបែងចែកជាពីរដែរទេ ខ្មាំងខាងកើត ខ្មាំងខាងលិច អ៊ីចឹងដែរទេ?

**ឆ៖** ខ្ញុំចាំគាត់លើកពីរឿងខ្មាំងខាងលិច និយាយចំពោះថា ខាងប្រទេសថៃ។ ពេលនោះគាត់បញ្ជាក់ថា ខាងព្រំដែនសៀម គឺមានបញ្ហាត្រង់ថាជាពួកមួយចំនួន វាចូលលួចកាប់ឈើនៅតាមព្រំដែនអីជាបន្តបន្ទាប់។ ប៉ុន្តែខ្មាំងនេះមិនខ្លាំងទេ ព្រោះពួកនេះវាចាញ់ដៃកងទ័ពរបស់យើង ដែលឈរការពារអធិបតេយ្យភាពរបស់នៅចំណុចទាំងអស់នេះ។ ដោយសំអាងថា វាជាទាហានមួយដែលមិនធ្លាប់ជួបការ ជួបប្រទះនឹងការប្រយុទ្ធស្វិតស្វាញ។ តែគាត់ឲ្យប្រុងប្រយ័ត្នចំពោះខ្មាំងខាងកើត ដែលជាខ្មាំងស៊ីជម្រៅក្នុងទឹកដីកម្ពុជាផង ហើយខ្មាំងប្របិចទឹកដីកម្ពុជាតាមព្រំដែន និងដែនទឹក និងដែនគោកកម្ពុជាផង។

**ស៖** សូមអរគុណលោកសាក្សី ចំពោះការបំភ្លឺនេះ។ មួយទំព័រទៀតមុខទៀតនៅក្នុងសុន្ទរកថាដដែលរបស់ សុន សេន នេះគឺ ERN ជាអង់គ្លេស00940343, បារាំង00334976, ខ្មែរ00652406។ គាត់បាននិយាយដូចតទៅ ទៅកាន់មេបញ្ជាការ<ទាំងពីរនៃ>កងពល១៦៤របស់លោក និងអ្នកដទៃទៀត។ ខ្ញុំសូមដកស្រង់៖ “ខ្មាំងទី២ គឺខ្មាំងពីខាងកើត។ ផែនការខ្មាំងពីខាងកើតនេះ គឺ<វៀតណាម> ដែលមាន សូវៀតនៅពីខាងក្រោយ គឺគេនឹងវាយពីខាងផ្ទៃក្នុង <តាមរយៈ>ទ័ពរបស់<ជនក្បត់> យ៉ា, កែវ មាស, ឈូក និង ចក្រី។ អ្វីដែលគេចង់បានពីការវាយប្រៀបពីខាង<ក្រៅ> គឺ<ការវាយប្រហារតាមបែប>ឆេកូស្លូវ៉ាគី <និងអង់ហ្គោឡា [...]។” និងបន្តទៅទៀត។ លោកសាក្សី លោកនៅចាំ សុន សេន និយាយអំពីផែនការសំខាន់ៗរបស់វៀតណាម ដើម្បីវាយប្រហារកម្ពុជាប្រជាធិបតេយ្យពីខាងក្នុងនោះមកដែរទេ?

[១៣:៤២:២៤]

**ឆ៖** តាមខ្ញុំចាំ ពេលនោះគាត់លើកពីរឿងថា ក្នុងកម្ពុជាយើងមានភ្នាក់ងារសំខាន់របស់ផ្ទៃក្នុងកម្ពុជាហ្នឹង គឺមានភ្នាក់ងាររបស់សូវៀត របស់វៀតណាម។ ហើយនៅក្នុងហ្នឹងកិច្ចសហការរបស់ភ្នាក់ងារទាំងអស់នេះ គឺជាកិច្ចសហការ ពេលនោះគឺថាហៅថា “បក្សសម្ព័ន្ធវ៉ាសូវី” របស់សហភាពសូវៀតដែលបានបង្កើតឡើងនៅក្នុងអាល្លឺម៉ង់ខាងកើតទាំងមូល។

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំនឹងបន្តទៅមុខទៀត។ ៦ខែក្រោយពីកិច្ចប្រជុំនេះ អនុបញ្ជាការកងពល១៦៤ ឌឹម ក៏ត្រូវបានចាប់ខ្លួន។ គាត់ត្រូវបានចាប់ខ្លួន ខ្ញុំជឿថានៅថ្ងៃទី២១ មេសា ១៩៧៧។ ខ្ញុំដឹងថាលោកមិនដឹងអំពីមូលហេតុនៃការចាប់ខ្លួន ឌឹម នេះទេ។ ប៉ុន្តែតើលោកមានបានឮពីកម្មាភិបាលផ្សេងៗ ឬក៏ពី សុន សេន និយាយនៅក្នុងអង្គប្រជុំនេះទេ ថាមូលហេតុអីបានជា ឌឹម ត្រូវបានចាប់ខ្លួន?

**ឆ៖** ពេលដែល ឌឹម ត្រូវបានចាប់ខ្លួន វាក្នុងសភាពការណ៍មួយដែលខ្លួនខ្ញុំ ព័ត៌មានមិនគ្រប់គ្រាន់ទេ ព្រោះការគិតពិនិត្យសកម្មភាពទៅ ខ្ញុំឃើញថាពេលនោះខ្ញុំក៏មិនអាចដឹង អ្នកផ្សេងទៀតក៏មិនអាចដឹង ព្រោះវាជាកិច្ចការផ្ទៃក្នុង។ ពេលនោះបញ្ជាក់ថា កម្មាភិបាលថ្នាក់ក្រោមមិនអាចយល់ដឹងពីកិច្ចការរបស់កម្មាភិបាលថ្នាក់កងពលទេ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី។ លោកសាក្សីនៅក្នុងចម្លើយរបស់លោក ដែលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាកំណត់ហេតុស្តាប់ចម្លើយ គឺថាគេមាននិយាយអំពីគោលការណ៍លាក់ការណ៍សម្ងាត់។ តើគោលការណ៍លាក់ការណ៍សម្ងាត់ហ្នឹង មាន<ន័យថា>កម្មាភិបាលជាន់ទាប កម្មាភិបាលថ្នាក់ទាប<មិនត្រូវបានគេជូនដំណឹង>អំពីមូលហេតុនៃការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ណាម្នាក់ទេ?

**ឆ៖** តាមគោលការណ៍សម្ងាត់ គឺគេមិនបាននិយាយប្រាប់ទេ ព្រោះកិច្ចការសម្ងាត់ក្នុងន័យថាអ្នកណាធ្វើអ្នកហ្នឹងដឹង។ ភារកិច្ចរបស់អ្នកណា អ្នកហ្នឹងទទួលខុសត្រូវ។ ដូច្នេះ ខ្ញុំក៏មិនមានកិច្ចការអីទៅយល់ដឹងពីកិច្ចការអ្នកផ្សេងដែរ។ នេះជាផែនការសំខាន់ៗរបស់ខ្លួនខ្ញុំ ក៏ដូចជាអ្នកផ្សេង។

[១៣:៤៦:១១]

**ស៖** ខ្ញុំយល់ហើយដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។ ប៉ុន្តែក្រោយៗមកទៀត ប្រហែលជាក្នុង<ក្រោយ>ឆ្នាំ១៩៧៩ក្តី តើលោកធ្លាប់បានឮថា ឌឹម នេះមានជាប់ពាក់ព័ន្ធទៅនឹងសមាជិកគណៈអចិន្ត្រៃយ៍ម្នាក់ឈ្មោះ វន វេត ដែរទេ?

**ឆ៖** តាមខ្ញុំដឹង ឯកសារនេះខ្ញុំក្រោយពីខ្ញុំមកជម្រាប ក្នុងឯកសារស៊ើបអង្កេតរបស់អង្គតុលាការវិសាមញ្ញកាត់ក្តីនេះ ខ្ញុំបានអាននូវឯកសារនេះ។ តែវាជាឯកសារប្រគល់ជូនដល់ខ្ញុំអាននៅពេលដែលយប់ទី២ ដែលខ្ញុំមើលឃើញថាមានឈ្មោះប៉ុន្មាននាក់ ដែលខ្ញុំបានចុះនៅក្នុងបញ្ជីឲ្យខ្ញុំធ្វើការចុចសម្គាល់ថា អ្នកណាខ្លួនខ្ញុំបានស្គាល់ខ្លះ ខ្ញុំចុះគូសវង់ រង្វង់មូលឲ្យខាងអង្គស៊ើបអង្កេតគាត់យល់ថា ខ្ញុំស្គាល់អ្នកណាខ្លះ។ ដូច្នេះខ្ញុំមានឈ្មោះនៅក្នុងហ្នឹង ខ្ញុំបានបញ្ជាក់ជូនដូចបង្ហាញក្នុងឯកសារស្រាប់។

**ស៖** ខ្ញុំមិនដឹងថាគេមានបង្ហាញឈ្មោះ វន វ៉េត នេះ<ដល់លោកឬទេ>។ ខ្ញុំសូមបន្តទៅមុខទៀតចុះ។ លោកសាក្សី សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងវគ្គរៀនសូត្រ ឬក៏អង្គប្រជុំដែលលោកក៏ដូចជាសមាជិកកងពល១៦៤ធ្លាប់បានចូលរួមប្រជុំជាមួយនឹង សុន សេន។ តើលោកនៅនឹកឃើញទេ ថានៅក្នុងអង្គប្រជុំទាំងនោះ សុន សេន មាននិយាយអំពីរដ្ឋប្រហារ ឬក៏រដ្ឋប្រហារយោធាកើតឡើងនៅភ្នំពេញមានបំណងដើម្បីៗទម្លាក់ ប៉ុល ពត ដែរទេ?

**ឆ៖** ព័ត៌មាននេះខ្ញុំបានទទួលការធ្វើបទបង្ហាញរបស់គាត់ តែមិនច្បាស់ថា តើកងពលណាលេខប៉ុន្មាន មានគ្នាប៉ុន្មាន មានគំនិត និងផែនការធ្វើរដ្ឋប្រហាររំលំ ប៉ុល ពត ទេ ព្រោះវាជាឯកសារដែលលើកធ្វើសន្និបាតនៅពេលបើកវគ្គបណ្តុះបណ្តាល វគ្គនយោបាយដល់នាយទាហាន និងពលទាហានក្រោមកិច្ចបញ្ជារបស់គាត់ផ្ទាល់។

[១៣:៤៩:២១]

**ស៖** ហើយតើលោកនៅចាំទេ គាត់និយាយតែរដ្ឋប្រហារមួយលើក ឬក៏រដ្ឋប្រហារបួនប្រាំលើកដែលគម្រោងនឹងធ្វើនោះ? ហើយរដ្ឋប្រហារទាំងអស់ហ្នឹង គឺថាបរាជ័យទាំងអស់?

**ឆ៖** ខ្ញុំចាំពេលវេលាមិនច្បាស់ថា តើរដ្ឋប្រហារនោះមានប៉ុន្មានដង តែគ្រាន់តែជារួម ខ្ញុំយល់ដឹងថា មានផែនការរដ្ឋប្រហារ។

**ស៖** សំណួរពាក់ព័ន្ធទៅនឹង សុន សេន ដដែល។ តើលោកដឹងទេថា លេខកូដប៉ុន្មានដែល សុន សេន បានប្រើប្រាស់នៅក្នុងសារទូលេខ ឬក៏ក្នុងសារទូរលេខផ្ញើមកឲ្យគាត់? តើគេប្រើលេខកូដប៉ុន្មានដើម្បីបញ្ជាក់តំណាងឲ្យ សុន សេន?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែពេលនោះ ខ្ញុំដឹងលេខមួយដែលថា តែងកម្មាភិបាលថ្នាក់លើរបស់ខ្ញុំប្រាប់ថាជាសេចក្ដីសម្រេចរបស់៨៧។

**ស៖** ហ្នឹងគឺជាចម្លើយទៅនឹងសំណួររបស់ខ្ញុំហើយ។ នៅក្នុងសារទូរលេខ ឮសួរគេហៅ សុន សេន ថាបង៨៩ <ប៉ុន្តែក៏ហាក់ដូចជាគេហៅ>ថា បង៨៧<ផងដែរ>។ ដូច្នេះសំណួររបស់ខ្ញុំសួរ ថាតើបង៨៧ជាអ្នកណា?

**ឆ៖** សារទូរលេខរបស់៨៧ តាមខ្ញុំចាំ ថាជាសាររបស់ថ្នាក់លើ។

[១៣:៥១:៤២]

**ស៖** ខ្ញុំគិតថា អ៊ីចឹងដែរ ប៉ុន្តែថាតើវាអាចជាអគ្គសេនាធិការរង នៅខាងក្រោម សុន សេន ឬក៏

ជាលេខកូដតំណាងឲ្យអ្នកណាម្នាក់ដែលលោកមិនបានដឹង?

**ឆ៖** ខ្ញុំមិនបានដឹងដែរ ព្រោះថាលេខនេះ ក្នុងក្របខ័ណ្ឌថ្នាក់ដឹកនាំរបស់ខ្ញុំដែលនៅខាងលើ គឺមានវរសេនាធំ គាត់ថា ៨៧បានសម្រេចយ៉ាងណាៗ អាហ្នឹងគឺគាត់បានប្រាប់ថា ជាមតិរបស់៨៧។

**ស៖** សូមអរគុណលោកសាក្សី។ នៅសល់តែ១០នាទីទៀតទេ គ្របដណ្តប់ទៅលើប្រធានបទពីរ។ ខ្ញុំសូមយោងទៅកំណត់ហេតុស្តាប់ចម្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោក។ <តើ> លោកនៅចាំ លោកនិយាយអំពីការលំបាកក្នុងការទាក់ទងគ្នា ដោយប្រើវិទ្យុទាក់ទងរបស់ចិននៅលើទូក និងឧបករណ៍របស់អាមេរិកាំង ដែលប្រើប្រាស់នៅលើដីនៅកំពង់សោម លោកនៅចាំទេ?

**ឆ៖** ខ្ញុំចាំ ព្រោះពេលនោះខ្ញុំនៅនាវារបស់ចិន ប្រើប្រព័ន្ធមួយផ្សេង ហើយគេអូ ឬក៏ថាទូរស័ព្ទនៅខាងគោក គឺប្រើប្រព័ន្ធផ្សេង។ អ៊ីចឹងអាការទាក់ទងគ្នាគឺមានការលំបាក។

**ស៖** ដូច្នេះទូក ឬក៏កប៉ាល់របស់ចិនល្បាតនៅទឹកសមុទ្រជុំវិញកោះពូលូវ៉ៃ ឧទាហរណ៍ តើវាមានការលំបាកសម្រាប់កងទ័ពនៅលើទូកប្រាស្រ័យទាក់ទងគ្នា ជាមួយនឹងទីបញ្ជាការនៅឯកំពង់សោមនេះដែរទេ?

**ឆ៖** តាមការធ្លាប់ប្រើរបស់ខ្ញុំកន្លងទៅ គឺប្រព័ន្ធទីបញ្ជាការរបស់កំពង់សោម និងប្រព័ន្ធអនុវត្តជាក់ស្តែងនៅលើនាវា គឺប្រើប្រាស់ដោយប្រព័ន្ធទាក់ទងតាមទូរលេខ ជាលេខរបស់នាវានីមួយៗ គឺប្រើទូរលេខ ហើយបានបកចេញជាតួអក្សរមកវិញ។

[១៣:៥៤:៥៤]

**ស៖** ប៉ុន្តែនាវាល្បាតដែលបានពីចិន តើវាមានការលំបាកអីទេ នៅពេលដែលល្បាតនៅលើទឹកហ្នឹង? ហើយតើគេត្រូវធ្វើការទាក់ទងជាមួយទីបញ្ជាការកងពលនៅកំពង់សោមដោយរបៀបណា?

**ឆ៖** ការប្រើប្រាស់នាវារបស់ចិន ដែលផ្តល់ឲ្យខ្ញុំ តាមខ្ញុំបានមានពិសោធន៍ប្រើ គឺការប្រើប្រាស់របស់វាងាយស្រួលក្នុងការបើកបរ ហើយការទាក់ទងក៏មិនការអីលំបាកដែរ ព្រោះប្រព័ន្ធទូរលេខដែលខាងចិនផ្តល់មកហ្នឹង គឺវាស្របគ្នា ព្រោះការហ្វឹកហ្វឺនរបស់យុទ្ធជនទូរលេខ ដែលនៅក្នុងនាវា ហើយនិងយុទ្ធជនទូរលេខដែលនៅទីបញ្ជាការគេយល់ ហើយគេប្រើប្រាស់ដោយ ដូចថាទាក់ទងគ្នាបានងាយស្រួល។

**ស៖** សូមអរគុណ។ ប្រធានបទចុងក្រោយលោកសាក្សី តើគេត្រូវធ្វើយ៉ាងម៉េចជាមួយនឹងជនភៀសខ្លួន ឬក៏អ្នកនេសាទមកពីថៃ? ចុះប្រសិនណាទូកនេសាទថៃចូលមកដែនទឹករបស់កម្ពុជាប្រជាធិប

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តេយ្យ តើគេមានណែនាំបង្គាប់ឲ្យធ្វើយ៉ាងម៉េចដែរ?

**ឆ៖** តាមការឮជាព័ត៌មានទេ មិនមែនផ្ទាល់ខ្លួនខ្ញុំបានប្រើប្រាស់នាវា ឬក៏កងនាវារបស់ល្បាតនេះទៅធ្វើផ្ទាល់ទេ ព្រោះកងនាវានេះ វាកិច្ចការប្រើប្រាស់ មិនទាន់ប្រើប្រាស់ក្នុងភាពជាអ្នករៀបចំល្បាតនៅក្នុងផ្ទៃសមុទ្រទាំងមូល ទាំងស្រុងទេ ព្រោះពេលវេលាវាខ្លី ហាត់ហ្វឹកហ្វឺនមួយឆ្នាំ។ ដូច្នេះពេលវេលាមិនគ្រប់គ្រាន់ក្នុងការរៀបចំឲ្យទៅជាប្រព័ន្ធនៅឡើយទេ ទី១។ ទី២ ការដែលក្រុមនេសាទរបស់ថៃចូលមក អ្វីទាំងអស់ហ្នឹង គឺមានទូកនិងនាវារបស់យុទ្ធជននៅតាមកោះ អាហ្នឹងគេអនុវត្តផែនការដេញ ឬក៏បញ្ឈប់ការរុលចូលរបស់កងនេសាទថៃ ឬក៏ពួកកាណូត ទូករបស់ថៃដែលចូលមកក្នុងអធិតេយ្យកម្ពុជា ដូចខ្ញុំបានទទួលព័ត៌មានតាមវិទ្យុទាក់ទង ឮថាមានថ្ងៃមួយនោះ គឺទូកថៃច្រើនគ្រឿងចូលមករំលោភដែនអធិបតេយ្យភាពដែនទឹក ហើយបានយក កាលហ្នឹងនៅសល់នាវាមួយ គេហៅនាវារបស់អាមេរិកដែលបោះប្រចាំប្រើប្រាស់សម្រាប់ទាហានលន់ នល់ គេហៅថា ខ្ញុំប្រើពាក្យបារាំងថា "ប៉េសង់អុង"។ វាចេញទៅប្រតិបត្តិការ ហើយបើកាលណាឃើញនាវាហ្នឹងចេញទៅ គឺខាងថៃ គឺគេដកខ្លួនថយទៅដែនទឹករបស់គេវិញ។

[១៣:៥៩:០៣]

**ស៖** សូមអរគុណ។ ខ្ញុំយល់អំពីស្ថានភាពដែលទូកនេសាទរបស់ថៃត្រូវបានបញ្ឈប់ ត្រូវបានឃាត់ ហើយជនជាតិថៃហ្នឹង ត្រូវបានគេយកមកលើគោក ដើម្បីសួរចម្លើយ។ នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានបញ្ជាក់ថា នៅពេលដែលគេសួរអ្នកទាំងនោះរួចហើយ បញ្ហានឹងត្រូវដោះស្រាយ ដកស្រង់៖ "តាមការទូត"។ តើលោកចង់និយាយថា យ៉ាងម៉េចដែលថាបញ្ហាជាមួយជនភៀសខ្លួនថៃ គឺថានឹងត្រូវដោះស្រាយតាមការទូត?

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ យើងព្យាយាមអត់ធ្មត់ណាស់ ហើយខ្ញុំគិតថាមេធាវីទៅលឿនណាស់។ គាត់មិនបានដកស្រង់ប្រភពឲ្យបានច្បាស់លាស់ គឺគាត់សង្ខេបចម្លើយរបស់សាក្សីដោយមិនបានដកស្រង់សម្ដីពិតប្រាកដរបស់សាក្សីទេ ហើយសូមឲ្យសាក្សីរូបនេះបញ្ជាក់។ គាត់គួរតែដកស្រង់

ឃ្លាពិតប្រាកដរបស់សាក្សីតែម្តង ដែលគាត់ឆ្លើយថាយ៉ាងម៉េចខ្លះ គាត់មិនគួរសង្ខេបចម្លើយហើយយកមកសួរអ៊ីចឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនបញ្ហាទេលោកប្រធាន។ ខ្ញុំយោងទៅរក <E3/9113> ERN អង់គ្លេស 00--

**អ្នកបកប្រែ៖**

លោកប្រធានសូមអភ័យទោស គាត់លឿនពេកមិនទាន់បាទ។

**ប្រធានអង្គជំនុំ៖**

លោកៗ វ៉ិចទ័រ កូប៉េ បញ្ជាក់លេខ ERN សាជាថ្មីម្តងទៀត លោកនិយាយលឿនពេក អ្នកបកប្រែ បកប្រែមិនទាន់ទេ។

[១៤:០១:០៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺ E3/9113, 00974221 ខ្ញុំនឹងជូនខ្មែរERN ក្នុងពេលបន្តិចទៀតនេះ។ អ្វីដែលគាត់និយាយលោកប្រធានគឺដូចខាងក្រោមនេះ៖ "ខ្ញុំទទួលការណែនាំថា នៅពេលដែលនាវាចូលមកដែនទឹកសមុទ្រយើង យើងត្រូវតែចាប់ ហើយរាយការណ៍ទៅលើដើម្បីឲ្យដោះស្រាយបញ្ហាតាមការទូត។" ហើយខាងក្រោមបន្តិច គឺថាគាត់និយាយយោងទៅដល់ការពិភាក្សាការទូត។ ប្រភពមួយផ្សេងទៀតគឺ <E3/2314> អង់គ្លេស ERN 00165983, បារាំង 00768209, ខ្មែរ <00722466> <និង 467> គឺរបាយការណ៍សារព័ត៌មាន និយាយអំពីការព្រមព្រៀង<រវាង>កម្ពុជាប្រជាធិបតេយ្យជាមួយប្រទេសថៃ អំពីការបញ្ជូនអ្នកនេសាទ<ថៃ>ត្រឡប់ទៅវិញ គឺជាកតិកាសញ្ញាការទូត។ នេះជាប្រភព នេះជាឯក-សារដែលខ្ញុំយោង។ អ៊ីចឹងជាសំណួរចុងក្រោយរបស់ខ្ញុំពីរបីទៀត លោកសាក្សី តើលោកដឹងអ្វីខ្លះអំពីការពិភាក្សាការទូត<រវាងថៃ និងកម្ពុជាប្រជាធិបតេយ្យ>ទាក់ទងទៅនឹងអ្នកនេសាទថៃ ដែលថាគេចាប់បានហើយយកមកនៅលើឆ្នេរសមុទ្រ? តើមានការពិភាក្សាការទូតអ្វីខ្លះទាក់ទងទៅនឹងអ្នកនេសាទទាំងនោះ?

[១៤:០២:៥៧]

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** ខ្ញុំជម្រាបថាពិភាក្សាការទូត ខ្ញុំដឹងតាមព័ត៌មានដែលថ្នាក់វរសេនាធំខ្ញុំបានបញ្ជាក់ថា អ្វីដែលកើតមាននៅដែនសមុទ្រ យើងចាប់បានទូកនេសាទថៃក្តី ទូកណាក្តី គឺយើងត្រូវប្រគល់ជូនទៅផ្នែក

ទាក់ទងអន្តរជាតិដើម្បីឲ្យក្រុមពួកនេសាទទាំងអស់នេះ ដោះស្រាយយ៉ាងណាៗទៅតាមកិច្ចការរបស់ក្រសួងការបរទេស។ តែកិច្ចការនេះសម្រេចយ៉ាងណា ខ្ញុំមិនបានដឹងច្បាស់លាស់ថាឃើញនឹងភ្នែកទេ ហើយក៏មិនបានស្ដាប់ឮដល់ផ្ទាល់ត្រចៀកដែរ គឺថាគ្រាន់តែឮតាមរយៈការបញ្ជាក់របស់ថ្នាក់ដឹកនាំជាវរសេនាធំ ឬវរសេនាតូចរបស់ខ្លួន គាត់បានប្រជុំ និងប្រាប់។

**ស៖** តើលោកធ្លាប់បានឮ ថាតើអ្នកនេសាទថៃភាគច្រើន ឬក៏ទាំងអស់ត្រូវបានដោះលែងនៅពេលណាមួយដែរឬទេ?

**ឆ៖** កិច្ចការហ្នឹង ខ្ញុំគ្រាន់តែឮថាបានបញ្ជូនទៅឲ្យក្រសួងការបរទេសរួចអស់ហើយ។ ដូច្នេះអ្វីដែលខ្ញុំឃើញថា បញ្ជូនតាមណាទៅច្រកណា ខាងខ្ញុំអត់បានយល់ដឹងទេបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:០៥:០៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំមិនអាចជំទាស់ទាន់ ដោយសារតែខ្ញុំកំពុងរង់ចាំការបកប្រែភាសាបារាំង វាយឺតទៅហើយ ដោយសារសាក្សីឆ្លើយទៅហើយ។ ខ្ញុំគិតថា សំណួរហ្នឹងជាសំណួរទូទៅ មិនមានរយៈកាលអ្វីច្បាស់លាស់ទេ។ ហើយគាត់និយាយថា នៅពេលណាមួយនោះត្រូវបានដោះលែង។ អ៊ីចឹងអត់ច្បាស់ មិនដឹងថា គាត់សំដៅទៅឆ្នាំណា ពេលណាឲ្យច្បាស់។ ខ្ញុំគិតថា គាត់គួរតែបែងចែករយៈកាលឲ្យបានច្បាស់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនជនជាតិថៃនេះ។

**ប្រធានអង្គជំនុំ៖**

គួរតែទុកពេលវេលាពេលលោកសួរទៅ លោកនឹងប្រើពេល ប្រើសំណួរនេះសួរបន្ថែមទៅ បើប្រសិនបើលោកមានភាពចាំបាច់ក្នុងការចង់ដឹងបញ្ហានេះឲ្យបានច្បាស់លាស់នោះ ព្រោះឱកាសលោកត្រូវសួរនៅពេលម៉ោងបន្ទាប់នេះហើយ។ បាទ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ បន្តទៀត!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបញ្ចប់សំណួររបស់ខ្ញុំ ប៉ុន្តែមានចំណុចពីរ ដែលខ្ញុំនៅជំពាក់ ខ្មែរ ERN នៃសេចក្ដីដកស្រង់សម្ភាសរបស់គាត់ទៅ ឌី.ស៊ី.ខេម <ដែលនិយាយពីការដោះស្រាយបញ្ហាតាមកាទូត> គឺ 00926398។ ហើយចំណុចទី២ របស់ខ្ញុំនោះ គឺបញ្ហានៃការសុំបំភ្លឺ គឺសំណើសុំឲ្យ ដែលខ្ញុំចង់ស្នើសុំប្រើ

ព្រឹកមិញនេះ ហើយខ្ញុំក៏សុំឱ្យដាក់ឯកសារនេះបញ្ចូលជាភស្តុតាង។ យើងខ្ញុំបានធ្វើសំណើផ្ទាល់មាត់រួចមកហើយ ប៉ុន្តែ<តាមខ្ញុំចាំគឺ>សំណើរបស់ខ្ញុំនៅកំពុងរង់ចាំការសម្រេច។ <ដូច្នេះសង្ឃឹមថា មុនពេលសាក្សីសម្រាប់សប្តាហ៍ក្រោយចូលមកបង្ហាញខ្លួននោះ> អង្គជំនុំជម្រះ<នឹងមានឱកាស>សម្រេច<ទៅលើសំណើនេះ>។ គឺថាលោកសាក្សី គឺថាខ្ញុំសូមអរគុណ។

[១៤:០៧:០៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សំណើផ្ទាល់មាត់របស់លោកហ្នឹង ក៏ត្រូវតែមានសំអាងហេតុ មូលហេតុផង។ <តើលោកកំពុងតែនិយាយពីអ្វីដែលលោកបាននិយាយមុនពេលឈប់សម្រាកនោះ ដែលជាមូលដ្ឋានខ្ញុំចង់>ទទួលស្គាល់តាមវិធាន៨៧(៤) <>?

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំមិនចង់លួចម៉ោងពីសហភាតាខ្ញុំទេ។ ប៉ុន្តែ>ភាពពាក់ព័ន្ធនៃឯកសារ ឌី.ស៊ី.ខេម នេះគឺ<ពីទំព័រទី១ភ្លាមៗតែម្តង។> គឺថាមេបញ្ជាការនៅក្នុងកងពល១៦៤នេះ <ដែលនិយាយលម្អិតអំពីអ្វីដែលកើតឡើងនៅក្នុងដែនសមុទ្រ។> គឺថាមានកំណត់ហេតុស្តាប់ចម្លើយពីរ <ពីសាក្សីរូបនេះក្នុងសំណុំរឿងផ្សេងទៀត។> គឺវាមានភាពច្បាស់លាស់ណាស់ ទាក់ទងទៅនឹងរចនាសម្ព័ន្ធបញ្ជាក្នុងកង<ពល១៦៤>។ អ៊ីចឹង<មិនមាន>មូលហេតុ<ជាដាច់ខាតក្នុងការគិតថា>ឯកសារនេះ<មិនមានអ្វីពាក់ព័ន្ធនឹងវគ្គពិសេសនេះនោះ>។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវី -- តំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការ -- ផ្តើមការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ មេធាវីនាំមុខ -- មេធាវី ខៀវ សំផន សួរមុន ឬក៏ប្រើពេលវេលាពេលក្រោយ ចុងក្រោយ?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំមានបញ្ហាកាសស្តាប់របស់ខ្ញុំ។ អត់ទេ លោកប្រធាន គឺដូចសព្វមួយដងអ៊ីចឹង នៅពេលដែលមេធាវីការពារក្តី នួន ជា ស្នើសុំកោះហៅសាក្សីណាមួយហ្នឹង គឺខ្ញុំសូមសួរចុងក្រោយគេ។ នេះជាគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ អរគុណ។ ហើយយើងក្តាប់បញ្ហានេះ យើងកំណត់ត្រឹមត្រូវហើយ ព្រោះអំមិញវាមានសកម្មភាពផ្សេង ដែលនាំឲ្យមានការបញ្ជាក់ឡើងវិញ ព្រោះយើងបានកំណត់បញ្ហានេះច្បាស់លាស់។ ហើយយើងយល់ដឹងពីបញ្ហានេះច្បាស់លាស់ណាស់ ហើយទាំងសំណើសុំរបស់លោកស្រីតាំងពីដើមរៀងមក។ អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៤:០៩:៣១]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំនឹងសួរសំណួរ<ទៅកាន់>លោក តាងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញានៅរសៀលនេះ និងថ្ងៃស្អែកទៀត។ ខ្ញុំឈ្មោះ វាំងសង់ ដឺវីល សូមលោកស្តាប់សំណួរឲ្យច្បាស់ ប្រសិនបើលោកមិនយល់ សូមលោកប្រាប់ខ្ញុំថា លោកមិនយល់ ខ្ញុំនឹងសួរឲ្យច្បាស់ម្តងទៀត។ ខ្ញុំសូមរំឭកថា លោកនៅទីនេះជាសាក្សី។ លោកត្រូវតែនិយាយការពិត និងជួយឲ្យអង្គជំនុំជម្រះស្វែងរកការពិត។ លោកមិនមែនជាជនជាប់ចោទ ឬលោកនឹងមិនទទួលរងនូវការចោទប្រកាន់អ្វីទេ។ លោកសាក្សីឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីប្រធានបទដែលនិយាយកាលពីម្សិលមិញ ដោយមេធាវីការពារក្តី គឺរឿងរ៉ាវដែលកើតឡើងចំពោះទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់។ កាលពីម្សិលមិញលោកថា លោកបានចាកចេញពីភ្នំពេញសំដៅទៅកំពង់សោម នៅថ្ងៃបែកទីក្រុងភ្នំពេញ គឺថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ លោកថាលោកមិនបានប៉ះពាល់អ្វីទៅទាហាន លន់ នល់ ដែលលោកបានជួបប្រទះនៅតាមផ្លូវទេ។ ក៏ប៉ុន្តែនៅម៉ោង១៥:៤១នាទី លោកថា ក្រោយមកបន្ទាប់ពីលោកបានរៀនសូត្រនៅកំពង់សោម លោកបានស្តាប់ឮថា មន្ត្រីរដ្ឋការ និងទាហាន លន់ នល់ ត្រូវបានសម្លាប់ចោលនៅឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៦។ តើលោកបានស្តាប់ឮអ្វីខ្លះពាក់ព័ន្ធទៅនឹងការសម្លាប់មន្ត្រីរដ្ឋការ និងទាហាន លន់ នល់?

[១៤:១១:១៨]

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** តាមខ្ញុំឮ វាជាការឮតាមព័ត៌មានរបស់យុទ្ធជន ឬកម្មាភិបាលដែលនិយាយខាងក្រៅ មិនមែន

ជានិយាយនៅក្នុងអង្គប្រជុំ ឬក៏និយាយនៅក្នុងក្របខ័ណ្ឌដែលមានការប្រជុំ ឬសន្និបាតអីមួយនោះទេ។

**ស៖** តើកម្មាភិបាល ឬយុទ្ធជនទាំងអស់នេះនិយាយអ្វីខ្លះនៅក្រៅកិច្ចប្រជុំនោះ ពាក់ព័ន្ធទៅនឹងការសម្លាប់ទាហាននិងមន្ត្រីរដ្ឋការនៃរបបលន់នល់នោះ? ពួកគេនិយាយនៅកន្លែងណាដែរ ឧទាហរណ៍? ហើយគេសម្លាប់អ្នកទាំងអស់ហ្នឹង សម្លាប់នៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំឮគេនិយាយថា ការសម្លាប់ទាហានលន់នល់ ហ្នឹងគឺជាការសម្លាប់ក្នុង គេលើកឧទាហរណ៍ថា គេដើរមកតាមផ្លូវដូចជានៅកន្លែងមួយ គេឃើញសាកសពពីរនាក់នៅខាងលិចកំពង់សិលា។ កម្លាំងដែលដើរមកតាមក្រោយខ្ញុំហ្នឹង គេប្រាប់ខ្ញុំអ៊ីចឹង។ ដូច្នេះខ្ញុំឮ តែខ្ញុំបានប្រាប់គេថា ពេលដែលខ្ញុំដើរមក ខ្ញុំអត់មានឃើញទេ។ អ៊ីចឹងអ្វីដែលនិយាយគ្នាក្នុងក្របខ័ណ្ឌនិយាយជាមនុស្សស្គាល់គ្នាជាកម្មាភិបាល ឬក៏ជាយុទ្ធជន តែខ្ញុំមិនចាំឈ្មោះថា ពេលនោះខ្ញុំនិយាយជាអ្នកណា ហើយមកដល់ថ្ងៃនេះ ខ្ញុំចាំថា អ្នកនោះនៅឯណា។ ហ្នឹងខ្ញុំគ្រាន់តែថា វាជាការចងចាំរបស់ខ្ញុំ។ កាលនោះវាយូរឆ្នាំហើយ។

**ស៖** ពេលដែលលោកចាកចេញពីភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ នោះ តើខ្ញុំអាចនិយាយបានទេថា លោកមិនដឹងទេថា<>មានរឿងអ្វីកើតឡើងចំពោះ<ទាហាន ឬ>អ្នកមានបណ្ដាស័ក្តិ<ខ្ពស់> នៃរបប លន់ នល់ នៅទីក្រុងភ្នំពេញនោះ?

[១៤:១៤:០០]

**ឆ៖** តាមការពិត ខ្លួនខ្ញុំអត់បានព្រាងថានឹងមានអ្វីកើតឡើងមែន ព្រោះពេលនោះខ្ញុំចេញដំណើរទៅ ដឹកនាំតែយុទ្ធជន ធ្វើម៉េចឲ្យដល់គោលដៅថា យើងទៅកាន់ទីក្រុងកំពង់សោម ដោយធ្វើតាមដំណើរតាមថ្មើរជើង។ ដូច្នេះមិនទាន់គិតថា តើមានទាហានលន់ នល់ បណ្ដាស័ក្តិថ្នាក់ណា ឬក៏យុទ្ធជនទាហានលន់ នល់ ថ្នាក់ណា ចំនួនប៉ុន្មាននាក់ត្រូវបានគេធ្វើឃាតធ្វើអី អាហ្នឹងខ្ញុំអត់បានគិតទេ ព្រោះភារកិច្ចពេលនោះ ខ្ញុំអត់មានទទួលការណែនាំ។

**ស៖** សូមអរគុណលោកសាក្សី។ សូមលោកឆ្លើយឲ្យបានខ្លីបន្តិចលោក។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សេចក្ដីសង្កេតទាក់ទងទៅនឹងបញ្ហានេះ គឺមិនទាន់ជាការជំទាស់

ទេ។ ខ្ញុំមិនជឿថាសាក្សីនិយាយពីម្សិលមិញអំពីការកាប់សម្លាប់<អ្នករដ្ឋការ>លន់ នល់ ទេ។ ខ្ញុំមិនប្រាកដទេ <នូវអ្វីដែលគាត់បាននិយាយ។> គាត់អាចនឹង<និយាយថាត្រូវបាន>សម្លាប់ ប៉ុន្តែជាក់ស្តែងនោះ គឺជាគោលការណ៍ ជាអំពើដែលប្រព្រឹត្តក្នុងពេលមានសង្គ្រាមទេ។ <ដូច្នេះ មានការខុសគ្នាយ៉ាងខ្លាំង ជាពិសេសនៅពេល>និយាយពីរយៈកាលខែមេសា ឆ្នាំ១៩៧៥ <ហើយនិងការ>និយាយអំពីការសម្លាប់<ដូចជាសកម្មភាពច្បាំងគ្នា វាផ្ទុយពីការសម្លាប់>ក្រៅ<>ច្បាប់នោះ<>។ អ៊ីចឹងសហព្រះរាជអាជ្ញា សូមឲ្យបំភ្លឺបញ្ជាក់បញ្ហានេះឲ្យបានច្បាស់។

[១៤:១៦:០០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំប្រើពាក្យ "សម្លាប់" នេះព្រោះថាពេលនុំង គឺភ្នំពេញត្រូវបានវាយបែកមកហើយ។ ដូច្នេះពេលនុំងលែងមានសង្គ្រាមអីទៀតហើយ។ ហើយកាលពីម្សិលមិញហ្នឹង គឺលោកមេធាវី វ៉ិចទ័រ កូប៉េ ខ្លួនឯងទេ នៅពេលដែលសួរសំណួរហ្នឹង លោកថាក្រោយចប់សង្គ្រាមហ្នឹង តើទាហាន លន់ នល់ ត្រូវបានគេសម្លាប់ដែរឬទេ ហើយមន្ត្រីរដ្ឋការហ្នឹងត្រូវបានសម្លាប់ដែរឬទេនៅ<ពាក់កណ្តាល>ឆ្នាំ៧៥ <ឬនៅក្នុងឆ្នាំ>៧៦។ អ៊ីចឹងគឺខ្លួនលោកទេ ដែលលោកជាអ្នកប្រើពាក្យហ្នឹងនោះ កាលពីម្សិលមិញនោះ។ លោកប្រធានខ្ញុំសូមអនុញ្ញាតបន្តទៅទៀត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី លោកដឹងទេថា មាស មុត ដែលជាមេបញ្ជាការកងពលលេខ៣<របស់លោក>នោះ គាត់មានបានទៅខេត្តកោះកុងជាមួយនឹងកងទ័ពរបស់គាត់ក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ទេ? លោកមានបានធ្លាប់ឮគេនិយាយបែបហ្នឹងទេ?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** តាមខ្ញុំចាំ រឿងនេះខ្ញុំអត់មានបានទទួលព័ត៌មានទេ ព្រោះពេលដែលខ្ញុំទៅដល់កំពង់សោមកិច្ចការរបស់ខ្ញុំ គឺមិនមានអីបានទទួលព័ត៌មានថា លោកមេទ័ព មាស មុត គាត់ទៅកោះកុងទេ ព្រោះអ្វីដែលខ្ញុំបញ្ជាក់ការងារនេះ គឺមិនមែនជា ខ្ញុំដឹងថាគាត់ទៅណាមកណា ខ្ញុំអត់យល់ថាគាត់មានភារកិច្ចអី។

[១៤:១៧:៥៧]

**ស៖** មុននេះលោកបាននិយាយថាទាហាននៅក្នុងកងពលរបស់លោកហ្នឹងនិយាយអំពីការសម្លាប់មនុស្សនៅក្រៅពេលប្រជុំ។ ចុះក្នុងពេលប្រជុំនោះ តើ មាស មុត ហើយនិងអនុកងពលរបស់គាត់ធ្លាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាននិយាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬសកម្មភាពរបស់កងទ័ពបដិវត្តន៍កម្ពុជាចំពោះមន្ត្រីរដ្ឋការជាន់ខ្ពស់ និងនាយទាហាននៃរបបសាធារណរដ្ឋខ្មែរដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ ពេលនោះ គឺគាត់មិននិយាយអំពីកិច្ចការ នាយទាហានបណ្តាស័ក្តិរបស់របប លន់ នល់ និងមន្ត្រីរាជការ អ្នករដ្ឋការទាំងអស់របប លន់ នល់ ទេ។ គាត់និយាយពេលប្រជុំ គាត់និយាយអំពីរឿងថា តើត្រូវការងារយើងដែលទទួលមកទីនេះ គឺត្រូវធ្វើអី គឺត្រៀមបម្រុងសម្រាប់ផ្ទាល់ខ្លួនខ្ញុំ និងអង្គភាព គឺសម្រាប់តែត្រៀមគ្រប់គ្រងនាវាថ្មី ដែលមិត្តចិនផ្តល់ជាជំនួយ។

**ស៖** ពាក់ព័ន្ធនឹងកោះកុងនេះ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់សាក្សីមួយរូបដែលបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ហើយដែលបានមកផ្តល់សក្ខីកម្ម<នៅចំពោះមុខអង្គជំនុំជម្រះនេះ>នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ នៅក្នុងផ្នែកផ្សេងនៃការជំនុំជម្រះក្តីនេះ។ <ខ្ញុំនឹងសួរលោកពាក់ព័ន្ធនឹងអ្វីដែលគាត់បាននិយាយ។> គឺសាក្សីឈ្មោះ អ៊ុល ហឿន ឬ ឯក ហឿន។ ខ្ញុំសូមយោងទៅលើឯកសារ E3/9582។ ខ្ញុំសូមដកស្រង់នូវសំណួរចម្លើយ៨៩ ពេលនោះគេសួរគាត់ដូចតទៅ៖ "ទាក់ទងនឹងរឿង មាស មុត នៅខែមេសា ឆ្នាំ៧៥ ក្រោយពេលខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជា គឺតាមុត ឬមាស មុត ទៅនៅកោះកុង ហើយបានបញ្ជាឲ្យទាហានលន់ នល់ ទាំងអស់ដាក់អាវុធចុះ។ ក្រោយមក ទាហានលន់ នល់ ទាំងអស់ត្រូវបានសម្លាប់ចោល។ នេះជាអ្វីដែលលោកបាននិយាយនៅក្នុងបទសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើត្រឹមត្រូវដែរឬទេ? ពេលនោះ ឯក ហឿន គាត់ឆ្លើយថា៖ បាទ ជាការពិត។ សំណួរទី៩២៖ ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកហាក់ដូចជាបានបញ្ជាក់ថា តាញ៉ាន់ ដែលជាកូនចៅរបស់ មាស មុត បានចាត់ចែងដឹកជញ្ជូនទាហាន លន់ នល់ ទៅសម្លាប់នៅក្នុងចម្ការផ្លែឈើ។ តើត្រឹមត្រូវដែរឬទេ? អ៊ុល ហឿន គាត់ឆ្លើយថា៖ បាទ ត្រឹមត្រូវ។ សំណួរ៩៦៖ តើមានឡានដឹកទាហានទាំងអស់នោះ ចំនួនប៉ុន្មាន? ចម្លើយរបស់ អ៊ុល ហឿន៖ កាំភ្លើងនិងសម្ភារៈ គឺមាស មុត ជាអ្នករក្សាទុក។ គេនិយាយថា នឹងបញ្ជូនអ្នកទាំងអស់នោះទៅផ្ទះវិញ។ ប៉ុន្តែតាមពិតគឺយកទៅសម្លាប់នៅក្នុងព្រៃ ក្បែរដើមដូង ដើមធូរេន ដើមស្វាយជាដើម។ សំណួរ១០៣៖ តើហេតុអ្វីបានជាលោកដឹងអំពីការសម្លាប់ទាហាន លន់ នល់ នៅកោះកុង? ចម្លើយរបស់ អ៊ុល ហឿន៖ ព្រោះមានការកងទ័ពចេញចូលច្រើន<ដង> ហើយពួកគេនិយាយអំពីរឿងនេះដូច្នេះទើបខ្ញុំដឹង។ ដំបូងគេឲ្យទាហានទាំងអស់នោះកាប់រណ្តៅនៅក្បែរដើមឈើជាមុនសិន។ បន្ទាប់មកទើបគេសម្លាប់ដាក់ក្នុងរណ្តៅនោះ ដើម្បីយកធ្វើជាជីតែម្តង។ និងជាចុងក្រោយ គឺចម្លើយ១០៩៖ មាស

មុត បានចេញបញ្ជាឲ្យសម្លាប់ទាហាននៅកោះកុងទាំងអស់។ នៅក្នុងខេត្តនីមួយៗ គឺមានចៅហ្វាយខេត្ត ជាអ្នកចេញបញ្ជាឲ្យសម្លាប់ទាហាន លន់ នល់ ទាំងអស់នោះ។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះតាមរយៈចម្លើយរបស់ អ៊ុល ហឿន នេះ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ឮគេនិយាយអំពីការសម្លាប់ទាហាន លន់ នល់ នៅខេត្តកោះកុងដែរឬទេ? គឺសមាជិកកងពលលេខ៣នោះ ក្រោយថ្ងៃទី ១៧ មេសា ឆ្នាំ៧៥ ធ្លាប់និយាយអំពីរឿងសម្លាប់ទាហាន លន់ នល់ ទេ នៅខេត្តកោះកុងនុ៎ង?

[១៤:២២:៤៥]

**ឆ៖** សូមជម្រាបថា នៅពេលនោះ ជាព័ត៌មាននេះ ខាងខ្ញុំអត់ដែលឮទេ។ ព្រោះកិច្ចការ សូម្បីតែ អ៊ុល ហឿន ដែលខ្ញុំស្តាប់សម្តីលោកទៅ ខ្ញុំយល់ថា ខ្ញុំមិនដែលស្គាល់គាត់ផង ហើយមិនដឹងជាគាត់ហ្នឹងនៅអង្គភាពណា ហើយគាត់ស្គាល់ មាស មុត ឬក៏ជាកូនទាហានរបស់ មាស មុត នៅពេលណា។ តែខ្ញុំសូមជម្រាបថា ខ្ញុំការងារដោយឡែក គ្មានអីពាក់ព័ន្ធ ហើយដឹងព័ត៌មានទាំងអស់នេះទេ ដោយខ្ញុំសំអាងលើភារកិច្ចរបស់ខ្លួនខ្ញុំ ការងារថ្មី ទទួលខុសត្រូវតែផ្នែករៀបចំ និងការហ្វឹកហ្វឺននាវា។

**សៈ** ចុះកំពង់សោមដែលស្ថិតនៅក្រោមអំណាចរបស់កងពល៣ និងកងពល១៦៤នោះ លោកដឹងថាមានរឿងហេតុអ្វីកើតឡើងចំពោះមន្ត្រីរដ្ឋការ<ជាន់ខ្ពស់> ឬក៏នាយទាហាននៅក្នុងក្រុងនោះ ក្រោយពីកម្លាំងខ្មែរក្រហមវាយយកក្រុងកំពង់សោមបានហើយនោះ?

**ឆ៖** ហេតុការណ៍ដែលនៅក្នុងក្រុងកំពង់សោម ខ្ញុំជាកងទ័ពនៅទីតាំងរបស់ខ្លួនខ្ញុំ ខ្ញុំអត់មានភារកិច្ចអីទៅធ្វើការងារជាផ្នែករដ្ឋបាល ឬក៏ថារៀបចំទីក្រុងអីនឹងគេដែរ ព្រោះអ្វីបានខ្ញុំនិយាយយ៉ាងនេះ ដោយខ្ញុំសំអាងថា សូម្បីតែខ្លួនខ្ញុំដើរចូលទីក្រុង ក៏អត់មានច្បាប់អនុញ្ញាត ក៏ខ្ញុំចូលអត់បាន។ អ៊ីចឹងអ្វីដែលខ្ញុំដឹង បានន័យថា ខ្ញុំមិនមែនខ្ញុំដឹងដោយភ្នែកខ្ញុំ ហើយឮដោយត្រចៀកខ្ញុំទេ ព្រោះកិច្ចការជា កិច្ចការមួយហ្នឹង គេហៅថាកិច្ចការរបស់ខ្ញុំវាដោយឡែក គេដោយឡែក។

**សៈ** កាលពីម្សិលមិញលោកថា កងពល១៦៤ បានក្លាយជាកងពលមជ្ឈិមនៅខែមិថុនា ឆ្នាំ ១៩៧៥។ ក៏ប៉ុន្តែកាលពីមុននោះ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកថាខែមិថុនា ឆ្នាំ ៧៦។ ដូច្នេះលោកអាចបញ្ជាក់បានទេ ថា<នៅខែមិថុនា> ឆ្នាំ៧៥ហ្នឹងមែនទេ <>នៅពេលដែលកងពល១៦៤ <>នេះបាន<ក្លាយ>ទៅជាកងពលមជ្ឈិម <និងបានប្តូរឈ្មោះពីកងពលលេខ៣ ទៅជាកងពល>

[១៤:២៦:០០]

**ឆ៖** សូមបញ្ជាក់ កងពល១៦៤ បានដាក់លេខថាជាកងទ័ពរបស់មជ្ឈិមនៅឆ្នាំ១៩៧៥ក្នុងខែមិថុនា។

**ស៖** ពេលដែលគេផ្ទេរលោកពីទាហានថ្មើរជើងនៃកងពល១៦៤ ទៅធ្វើជាកងទ័ពជើងទឹក គឺនៅក្នុង<វរសេនាធំ>១៤០ហ្នឹង គឺក្នុងពេលហ្នឹងហើយមែនទេ គឺប្រហែល<ជាខែមិថុនា> ឆ្នាំ៧៥ មែនទេ?

**ឆ៖** ការដែលផ្ទេរខ្លួនខ្ញុំចេញពីកងពលទី៣ ឡើងទៅរៀបចំអង្គភាពវរសេនាធំ១៤០ ខ្ញុំចាំបានថានៅក្នុងខែមិថុនា ឆ្នាំ១៩៧៥។

**ស៖** ខ្ញុំចង់សុំការបំភ្លឺមួយ កាលពីម្សិលមិញ ក៏ដូចជាថ្ងៃនេះ ខ្ញុំស្ដាប់ឮលោកនិយាយថា លោកជាអ្នកទទួលខុសត្រូវក្នុងការបណ្ដុះបណ្ដាលបច្ចេកទេសក្នុងកងទ័ពជើងទឹក។ ខ្ញុំមិនសូវយល់អំពីចំណុចនេះ។ ខ្ញុំចង់ដឹងថា ខ្លួនលោកផ្ទាល់ហ្នឹង លោកបានចូលរៀនបច្ចេកទេសក្នុងឋានៈជាមេបញ្ជាការនាវា ១៧១០ ឬក៏លោកជាអ្នកបង្រៀនទៅដល់នាវិកផ្សេងទៀត?

**ឆ៖** សូមបញ្ជាក់ ខ្ញុំដំបូងមិនមែននៅក្នុងនាវា១៧១០ទេ។ ខ្ញុំដំបូង គឺខ្ញុំនៅក្នុងក្របខ័ណ្ឌនាវា ១០០។ កាលហ្នឹងមកនាវាបួនគ្រឿង ១០១, ១០២, ១០៣, ១០៤ តែខ្ញុំជា ទទួលបន្ទុកហាត់ហ្វឹកហ្វឺន គ្រប់គ្រងយុទ្ធជននៅលើនាវាហ្នឹង ៣៨នាក់ នៅក្នុងផ្នែកអង្គភាពនាវា១០២ មិនមែន១៧១០ទេ។ ១៧១០ ជានាវាប្រគល់ឲ្យក្រោយ។ ហើយខ្ញុំមិនមែនជាអ្នកបង្ហាត់បង្រៀនទេ អ្នកដែលបង្ហាត់បង្រៀនដល់ពួកខ្ញុំពេលនោះ គឺជាគ្រូមកពីប្រទេសចិន ជាជនជាតិចិន។

[១៤:២៨:៥៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមដកស្រង់នូវចម្លើយលោកដែលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាគឺឯកសារ E3/9113 គឺទំព័រ២៦, ២៧ ជាភាសាអង់គ្លេស ហើយជាភាសាខ្មែរគឺ 00926361 ទៅដល់ 62។ ចំពោះអ្នកបកប្រែ ខ្ញុំសូមដកស្រង់ឃ្លានេះជាភាសាអង់គ្លេស ដោយសារតែមិនមានការបកប្រែជាភាសាបារាំងទេ។ សូមដកស្រង់៖ "ប្រធានអនុសេនាធំត្រូវបានជ្រើសរើសដើម្បីឲ្យទៅធ្វើជាគ្រូ។<សំណួរ៖> តើប្រធានអនុសេនាធំត្រូវបានជ្រើសរើស<ដើម្បី>បណ្ដុះបណ្ដាលឬ? លោកឆ្លើយថា៖ បាទ។" បន្ទាប់មកនៅទំព័រ២៧ សូមដកស្រង់៖ "គេបានបណ្ដុះបណ្ដាលយើងអំពីនាវាចរ ហើយនិងជួសជុលម៉ាស៊ីន ហើយនិងជួសជុលការថែទាំ អំពីការប្រើអាវុធ ចរន្តអគ្គិសនី ប្រព័ន្ធគមនាគមន៍ ទូរសារ ហើយនិងការឆ្លើយឆ្លង<តាមវិទ្យុទាក់ទង ឬតេអូ និងសញ្ញាទង់ជាតិ>ផងដែរ។" ហើយ<ចុះមកក្រោមបន្តិច> "គេធ្វើការបណ្ដុះបណ្ដាលហ្នឹងនៅឆ្នេរអូរឈើទាល នៅក្នុងឆ្នាំ១៩៧៦ ហើយវគ្គបណ្ដុះបណ្ដាល

ហ្វឹកហ្វឺននោះ គឺចំណាយពេល៦ខែ។" ចប់សេចក្ដីដកស្រង់។

ហើយនៅក្នុងកិច្ចសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដដែល គឺទំព័រ២៩ និង៣០ ជាភាសាបារាំង -- ជាភាសាអង់គ្លេស ហើយខ្មែរគឺ 00926364 ទៅ 65។ លោកបាននិយាយពាក់ព័ន្ធទៅនឹងពេលដែលចប់ការបណ្ដុះបណ្ដាលនៅឆ្នាំ៧៦។ លោកថាការបញ្ចប់ហ្នឹង គឺនៅ<ចុង>ឆ្នាំ៧៦ គឺ<ប្រហែលជានៅ>ខែសីហា ហើយបន្ទាប់ពីរៀនចប់ហ្នឹង លោកធ្វើការប្រចាំការនៅលើនាវា។ ដូច្នេះខ្ញុំអាចនិយាយបានថា នៅពេលដែលលោករៀនចប់នៅខែសីហា ឆ្នាំ៧៦នោះ គឺថាលោក គឺលោកនៅធ្វើការ<លើសពីពីរឆ្នាំ>នៅលើនាវា១៧១០ហ្នឹង<> ក្នុងឋានៈជាកាពីទែន ឬក៏ជាអ្នក<បញ្ជា>នាវានោះ។ តើអ៊ីចឹងមែនទេ?

[១៤:៣១:៣១]

**ឆ៖** សូមជម្រាប ក្រោយពីខ្ញុំទទួលខុសត្រូវនាវា១៧១០ ខ្ញុំជាប្រធាននាវា មិនមែនជាផ្នែកបើកបរទេ ប្រធានរួម បារាំងហៅថា "កាពីទែន"។

**ស៖** ចុះលោកមានបានទៅចិន ដើម្បីទៅរៀនសូត្រនៅទីនោះទេ ឬក៏ជាអ្នកផ្សេងទេដែលទៅរៀននៅចិននោះ?

**ឆ៖** សម្រាប់ពាក់ព័ន្ធក្នុងបច្ចេកទេសនាវា ខ្ញុំអត់មានទៅទេ ព្រោះចិន គាត់មកដល់កម្ពុជា គាត់បង្រៀនខ្ញុំនៅក្នុងអូរឈើទាល។ ហើយអ្នកផ្សេងដែលគេទៅ គេទៅរៀននាវាពីរគ្រឿង គឺគេហៅថានាវាប្រឆាំងនាវាមុជទឹក។ នេះជាភាសារបស់ខ្ញុំធ្លាប់ប្រើនៅក្នុងពេលដែលខ្ញុំនៅក្នុងកងនាវាចររបស់អូរឈើទាល។

**ស៖** ចុះនាវា១៧១០ របស់លោកនេះ តើជានាវាចម្បាំង នាវាប្រយុទ្ធ ឬក៏ជានាវាល្បាត? លោកអាចបញ្ជាក់ពីប្រភេទនាវាដែលលោកកាន់កាប់នេះទេ?

**ឆ៖** សូមបញ្ជាក់ នាវាខ្ញុំគ្រប់គ្រងនេះគឺជានាវា បើនិយាយតាមភាសាដែលខ្ញុំនៅប្រើក្នុងក្របខ័ណ្ឌកងនាវាចរ គេហៅថា "អង្គភាពនាវាការពារ" តែភារកិច្ចរបស់វា ជាភារកិច្ចល្បាតតាមដែនសមុទ្រ ក្នុងការបំពេញភារកិច្ចរបស់ខ្ញុំ។ ហើយនៅក្នុងឆ្នាំ១៩៧៦, ៧៦, ៧៨ ខ្ញុំបំពេញបេសកកម្មប្រគល់មុខសញ្ញាថ្នាក់លើបញ្ជាឲ្យខ្ញុំធ្វើការងារល្បាតនៅទិស គេហៅថា កោះថ្មី កោះសេះ ជាប់កោះត្រល់។

[១៤:៣៤:២១]

**ស៖** នៅក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយអំពីកោះប្ញស្សី និងកោះតាគារ។ តើកោះទាំងពីរហ្នឹងគឺស្ថិតនៅជិតកោះថ្មី <និងកោះសេះ>មែនទេ គឺនៅជិតឆ្នេរកម្ពុជា ហើយនិងនៅជិតកោះវៀតណាម កោះត្រល់មែនទេ?

**ឆ៖** សូមបញ្ជាក់ជូនអង្គសវនាការ។ កោះប្ញស្សី និងតាគារ វាជាកោះជាប់នឹងឆ្នេររាម ជិតផែរាម មានកោះប្ញស្សីមួយ មិនមែនកោះប្ញស្សីមួយដែលនៅខាងតំបន់កោះត្រល់ទេ ព្រោះវានៅក្នុងសមុទ្រហ្នឹងមានពីរ កោះប្ញស្សីមួយជាប់កោះត្រល់ កោះប្ញស្សីមួយវាជាប់នឹងកោះតាគារ នៅជាប់រាម។

**ស៖** បាទ សូមអរគុណ។ ក្រៅពីកោះទាំងបួននេះ តើគេមានបានបញ្ជូនលោកទៅកោះតាង កោះរ៉ុងសន្លឹម កោះពូលូវ៉ៃទេ?

**ឆ៖** ការពិតកោះតាង កោះពូលូវ៉ៃចាស់និងពូលូវ៉ៃថ្មី ហ្នឹងខ្ញុំពេលហ្វឹកហ្វឺននាវាគឺខ្ញុំធ្វើនាវាចរ ដោយគេហៅថាហាត់ហ្វឹកហ្វឺន បើកបរ ព្រោះត្រូវការហ្វឹកហ្វឺនដើម្បីឲ្យភាពជំនាញរបស់យើងដែលបានរៀនសូត្រ វាទៅជាការអនុវត្តជាក់ស្តែង។

**ស៖** ខ្ញុំចង់សួរសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងវរចនាសម្ព័ន្ធកងពល១៦៤។ លោកថាមាន មាស មុត ជាមេបញ្ជាការ ហើយមានឈ្មោះ ឌឹម ជាអនុបញ្ជាការ។ អ្វីដែលខ្ញុំចង់ដឹងនោះ ខ្ញុំចង់ដឹងថា តើនៅក្នុងវរសេនាធំ១៤០នេះ អ្នកណាជាមេបញ្ជាការ? ហើយអ្នកណាជាមេវរសេនាតូចរបស់លោក?

**ឆ៖** នៅកងវរសេនាធំ១៤០ គឺមានពីររូប។ ម្នាក់គាត់ឈ្មោះ បងសារឿន ហើយម្នាក់ទៀតគាត់មកពីបូព៌ាឈ្មោះ ស៊ម -- សំ។ ហើយវរសេនាតូចរបស់ខ្ញុំ គាត់ឈ្មោះ ហន។ ទាំងអស់ ទាំងបីរូបមកដល់ថ្ងៃនេះ ខ្ញុំដឹងថាគាត់ស្លាប់អស់ហើយ។

[១៤:៣៧:១៩]

**ស៖** លោកស្គាល់ឈ្មោះពេញរបស់ សារឿន ទេ តាំងត្រកូល និងឈ្មោះ? តើ<អាចថា>ឈ្មោះ <ង៉េត> ជឹម ហៅ សាមឿន តើជាមនុស្សតែមួយ ឬក៏ជាមនុស្សផ្សេង នៅពេលដែលលោកនិយាយ សារឿន ហ្នឹង? អ៊ីចឹងសូមលោកជួយប្រាប់ឈ្មោះពេញរបស់ សារឿន នេះទៅមើល?

**ឆ៖** ខ្ញុំចាំគាត់មិនបាន ប៉ុន្តែខ្ញុំស្គាល់ឪពុកគាត់។ ឪពុកគាត់ហ្នឹងឈ្មោះ កន តែមិនដឹងជាគាត់យក កន សារឿន ឬមួយក៏គាត់យកជីតា។ ខ្ញុំអត់ច្បាស់។ សូមបញ្ជាក់។

**ស៖** ចុះ ហម លោកស្គាល់ឈ្មោះពេញរបស់គាត់ទេ?

**ឆ៖** មិនមែនឈ្មោះ ហម ទេគឺគាត់ឈ្មោះ ហន។ តែត្រកូលរបស់គាត់ខ្ញុំអត់ច្បាស់ថាគាត់ជាស្អី

ហន ទេ។

**ស៖** នៅក្នុងវរសេនាធំ១៤០ <ជើងទឹក>ហ្នឹងមានមនុស្សទាំងអស់ប៉ុន្មាននាក់ដែរ?

**ឆ៖** ក្នុងវរសេនាធំ១៤០ ប្ញកសរួមកម្លាំងទាំងពីរ ចេញពីកងពលទី៣ចាស់ ហើយនិងមកពីភូមិភាគបូព៌ា សរុបទាំងអស់១.៤០០។

**ស៖** <ខ្ញុំយល់មិនសូវច្បាស់ទេ លោកបាននិយាយ>កាលពីម្សិលមិញ និងថ្ងៃនេះនោះ <ថាមាន>វរសេនាធំ<សរុបទាំងអស់ប៉ុន្មាននៅក្នុងកងពល១៦៤ ហើយបន្ថែមទៅនឹងវរសេនាធំទាំងនោះ> មាន<>វរសេនាតូច<ផ្សេងៗ>ទៀត<ដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់វរសេនាធំទេ>។ អ៊ីចឹងលោកអាចរៀបរាប់ពីចំនួនកងទ័ពនៅក្នុងវរសេនាតូចនីមួយៗបានទេ?

[១៤:៣៩:៤០]

**ឆ៖** ចំនួនកងទ័ពក្នុងវរសេនាតូចមួយៗ ខ្ញុំបានបញ្ជាក់ហើយថា មានបួនវរសេនាតូច ហើយក្នុងមួយវរសេនាតូចមានបីអនុសេនាធំ ក្នុងមួយអនុសេនាធំមាន១០០នាក់។

**ស៖** ចុះ<ភារកិច្ចរបស់វរសេនាតូច>៤៥០នេះ <>មានភារកិច្ចអ្វីដែរ? <តើវាស្ថិតនៅក្រោមវរសេនាធំ ឬក៏ជាវរសេនាតូចឯករាជ្យពីវរសេនាធំ? តើវាស្ថិតនៅក្រោមទីបញ្ជាការកងពល១៦៤ផ្ទាល់ឬ?>

**ឆ៖** កង៤៥០ អាហ្នឹងជាកង កាលនោះខ្ញុំនៅចាំបានថា ជាកងពិសេសរបស់កងពលប្រចាំជុំវិញកងពល១៦៤។

**ស៖** អង្គភាពពិសេស៤៥០នេះ គឺថានៅពេលដែលមានបញ្ហាវិន័យ ឬនៅពេលដែលមានការមិនគោរពបញ្ជា គឺកងពិសេស៤៥០ហ្នឹងហើយ ជាអ្នកចាប់ទាហាននៅក្នុងកងពល១៦៤ មែនទេ?

**ឆ៖** ខាងខ្ញុំមិនដឹងថាភារកិច្ចធ្វើអ្វីទេពេលនោះ តែខ្ញុំចាំបានថា ជាប់ឈ្មោះថាជាកងពិសេសហ្នឹង ដោយកងហ្នឹងជាកងពិសេសប្រចាំកងពលទី៣ ហើយលេខហ្នឹងក៏អត់លុបដែរ នៅរក្សាដដែល។ ដោយកងនេះកាលពីសម័យសង្គ្រាមមុនឆ្នាំ៧៥ មុនថ្ងៃ១៧ មេសា វាជាកងពលប្រយុទ្ធមួយ បញ្ជាដោយកងពល វាយប្រយុទ្ធក្នុងសមរភូមិកន្លែងណាដែរមានសភាពតានតឹងនៅមុខសញ្ញានីមួយៗ។

**ស៖** លោកប្រធានសំណួរចុងក្រោយមុនពេលឈប់សម្រាក។ តើកងវរសេនាធំណាដែលឈរជើងនៅកោះសេះ និងកោះថ្មី ដែលជិតនឹងកន្លែងប្រចាំការនៅក្នុងកងនាវារបស់លោកនោះ?

**ឆ៖** ខ្ញុំៗអាចមានអង្គភាពពីរដែលខ្ញុំមិនច្បាស់ថាតើ ខ្ញុំគិតថាដូចបើ៦២ ឬក៏៦៥ ខ្ញុំអត់ច្បាស់

តែខ្ញុំចាំច្បាស់ថាកងវរសេនាតូច -- វរសេនាធំមានបីសម្រាប់ប្រចាំលើកោះ។ មានកោះរ៉ុងធំ ហើយកោះតាង ពូលូវ៉ៃចាស់ ពូលូវ៉ៃថ្មី ហើយនិងកោះសេះ កោះថ្មី។ ចំណុចគោលដៅហ្នឹងមានកង ខ្ញុំបញ្ជាក់ក្នុងឯកសារ ខ្ញុំរៀបរាប់មាន៦១, ៦២, និង៦៣។ តែខ្ញុំមិនចាំថា ខ្ញុំភ្លេចថាតើ៦៣នៅកោះសេះ កោះថ្មី ឬមួយក៏យ៉ាងណា ខ្ញុំសូមអធ្យាស្រ័យ ព្រោះកាល វាពេលវេលាយូរពេក ចាំមិនអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:១១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការសំណួរនេះ ដល់ចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកបាននិយាយថា មាស មុត ជាមេបញ្ជាការកងពល១៦៤ ហើយនិង

<ឌឹម> ជាអនុកងពល មុនពេលគាត់ចាប់ខ្លួន។ តើ<មានសមាជិកគណៈកងពល១៦៤ផ្សេងទៀតទេ ហើយតើ>អ្នកណាខ្លះដែលស្ថិតនៅក្នុងគណៈកងពល១៦៤នេះ?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** ខ្ញុំសូមជម្រាប លោក មាស មុត ទី១។ មិនមែន ឌៀន ទេ គឺ ឌឹម ទី២។ ទី៣ ឆាន តែខ្ញុំចាំត្រកូលមិនបានទេ។ ហើយ៤ គឺ ញ៉ាន់ – តាញ៉ាន់។

**ស៖** តើការសម្រេច និងបញ្ជាផ្សេងៗពាក់ព័ន្ធទៅនឹងប្រតិបត្តិការរបស់វរសេនាធំ<ទាំងអស់នៃកងពល១៦៤> តើគឺអ្នកទាំងបួនដែលស្ថិតនៅក្នុងទីបញ្ជាការកងពលហ្នឹងហើយ ជាអ្នកចេញបញ្ជា និងសម្រេចផ្សេងៗនោះ មែនទេ?

**ឆ៖** អ្នកទាំងបួន ជាអ្នកចេញបញ្ជាសម្រាប់អនុវត្តទៅតាមមុខសញ្ញាដែលតម្រូវការ។ បញ្ជាទៅ១៤០ វរសេនាធំ១៤០ ក៏មានការសម្រេចដោយចេញពីកងពល ទៅអង្គភាព៦២, ៦៣, ៦១ ក៏ចេញបញ្ជាពីកងពលទាំងបួនរូប។

[១៥:០៦:២៣]

**ស៖** ដូច្នេះ ក្នុងប្រព័ន្ធបញ្ជាការនេះ លោកបាននិយាយអំពីបញ្ជាការកងពលដែលចេញបញ្ជាទៅកាន់វរសេនាធំផ្សេងៗ។ ដូច្នេះវរសេនាធំហ្នឹង បញ្ជូនបញ្ជាហ្នឹងទៅដល់ថ្នាក់ណានៅខាងក្រោមនោះ? ហើយលោកនោះ លោកទទួលបញ្ជាយ៉ាងម៉េចពីកងពល?

**ឆ៖** តាមការអនុវត្តបទបញ្ជាគឺកងពលបញ្ជាទៅវរសេនាធំ។ វរសេនាធំបញ្ជាទៅវរសេនាតូច។ វរសេនាតូចបញ្ជាចុះទៅកងអនុសេនាធំ។

**ស៖** ចុះការរាយការណ៍វិញ របាយការណ៍ហ្នឹង គឺថាចេញពីថ្នាក់ក្រោមទៅ ឡើងជាបន្តបន្ទាប់ទៅថ្នាក់លើ មែនទេ? មានន័យថា លោករាយការណ៍ទៅវរសេនាតូច វរសេនាតូចរាយការណ៍វរសេនាធំ ហើយវរសេនាធំរាយការណ៍ទៅកងពល អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន ព្រោះរាយការណ៍ពីក្រោមទៅលើ តាមថ្នាក់។ អនុសេនាធំទៅវរសេនាតូចនេះវាជាការរបៀបរបបរាយការណ៍របស់ពេលនោះ។

**ស៖** នៅក្នុងរចនាសម្ព័ន្ធដែលមានឋានានុក្រម<តឹងរ៉ឹងនេះ គឺរចនាសម្ព័ន្ធយោធា> តើកម្មាភិបាលថ្នាក់ទាប ឬក៏ថ្នាក់ក្រោមនៅក្នុងកម្រិតដូចលោកនេះ មានសិទ្ធិប្រកែកមិនគោរពបញ្ជា ធ្វើមិនដឹងមិនឮ ចំពោះបញ្ជាពីថ្នាក់លើមកទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពេលនោះ ក្នុងឋានៈខ្ញុំជាកងអនុសេនាធំ អ្វីដែលថ្នាក់លើដាក់ចុះ មិនមែនយើងគេចចេញពីបទបញ្ជាបានទេ ព្រោះការងារដែលត្រូវធ្វើ ដូចជាការងាររបស់ខ្ញុំ ខ្ញុំនិយាយក្នុងក្របខ័ណ្ឌខ្ញុំ ត្រូវធ្វើនាវាចរ បើកបរនាវា ត្រូវធ្វើ ត្រូវសម្រាកទៅតាមពេលវេលា ប៉ុន្មានថ្ងៃ ថាត្រូវហាត់ហ្វឹកហ្វឺន ប៉ុន្មានសម្រាកនេះវាជាបទបញ្ជា។ ដូច្នេះ ខ្ញុំធ្វើតាមការណែនាំ និងតាមបទបញ្ជា។

[១៥:០៩:៣៣]

**ស៖** ពាក់ព័ន្ធទៅនឹងប្រតិបត្តិការ តើមានការលើកលែងណាមួយដែលថាអាចឲ្យលោកមិនគោរពបញ្ជាទេ ឬក៏លោកដាច់ខាតត្រូវតែគោរពបញ្ជានៅក្នុងគ្រប់កាលៈទេសៈទាំងអស់?

**ឆ៖** ការអនុវត្តផែនការ ត្រូវធ្វើតាម ទៅតាមមានពេលវេលា ហើយអនុវត្តបទ -- មិនអនុវត្តបទបញ្ជា លុះត្រាតែបុគ្គលនោះមានធុរៈ ដោយមានធុរៈការឈឺថ្កាត់ ឬក៏មានការជាប់រវល់ការងារផ្សេង។ បើក្នុងករណីដែលនៅកន្លែង គ្រប់បុគ្គលដែលទទួលបានបទបញ្ជា មិនអាចបុគ្គលណាមួយ ដែលគេចចេញពីការងារអនុវត្តបទបញ្ជានោះឡើយ។

**ស៖** ចុះប្រសិនបើមានអ្នកណាម្នាក់មិនគោរពបញ្ជា គេធ្វើយ៉ាងម៉េចចំពោះអ្នកដែលមិនគោរពបញ្ជានោះ?

**ឆ៖** ក្នុងករណីដែលបុគ្គលអនុវត្តបទបញ្ជា ខ្ញុំនិយាយសំដៅលើ ការធ្វើការងារពេលដែលនោះមិនមែនជាការងារណាដែលយើងធ្វើមិនបានទេ ព្រោះជាក់ស្តែងដូចការងាររបស់ខ្ញុំ ទី១មានការហ្វឹកហ្វឺន ទី២មានការរៀនសូត្រ ប្រជុំការងារនៅក្នុងអង្គភាពរបស់ខ្លួនសម្រាប់តែអង្គភាពដែលខ្លួនគ្រប់គ្រង។

**ស៖** ខ្ញុំមិនបានទទួលចម្លើយពេញលេញរបស់លោកទេ។ ខ្ញុំចង់សួរលោកថា ចុះបើក្នុងករណីដែលមានការមិនគោរពបញ្ជាធ្ងន់ធ្ងរ ឧទាហរណ៍ដូចជាមេបញ្ជាការនាវាណាមួយ មិនព្រម<បញ្ឈប់> នាវាវៀតណាមដែលចូលដែនទឹកកម្ពុជានេះ តើគេធ្វើយ៉ាងម៉េចចំពោះមេនាវាហ្នឹង? គេមានដាក់ទណ្ឌកម្មអីដែរឬទេ?

[១៥:១២:២១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ពីព្រោះវាជាសំណួរឲ្យសាក្សីស្មានៗ ដែលយើងចាត់ទុកថាជាសំណួរប្រភេទឧបមានវិធី។ បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន មិនមែនអ៊ីចឹងទេ។ ខ្ញុំសួរឧទាហរណ៍ផ្សេងៗ ដែលគាត់អាចដឹងថាតើមានករណីដែលមានមេបញ្ជាការនាវាណាដែលមិនព្រមស្តាប់បញ្ជាដែរឬទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ដូច្នេះសូមលោកសាក្សីជួយឆ្លើយ ថាតើបើតាមអ្វីដែលលោកដឹងពីសម័យនោះ តាមបទពិសោធន៍លោកនោះ បើមានអ្នកណាម្នាក់មិនគោរពបញ្ជានោះ តើគេមានដាក់ទណ្ឌកម្មទេ នៅក្នុងកងពល១៦៤នេះ?

[១៥:១៣:១៨]

**ប្រធានអង្គជំនុំ៖**

តើអង្គហេតុនៃការដែលមាន គាត់បានដឹងអំពីថា មេបញ្ជាការនៃនាវាណាមួយដែលមិនគោរពវិន័យហើយឬនៅ? អាហ្នឹងហើយគឺឧបមានវិធីនោះ។ កាលណាយើង “ប្រសិនបើ” យើងឧបមា អាហ្នឹងឧទាហរណ៍មួយ ឧបមាមួយ ថាបើមានបញ្ហាអ៊ីចឹងវាកើតឡើង វាដោះស្រាយយ៉ាងម៉េច អាហ្នឹងវាឆ្លើយមកគឺវាជាឧបមានវិធី ឆ្លើយស្មានបាត់ហើយ។ ទាល់តែឡូវសួរថាអង្គហេតុហ្នឹងវាមានដែលៗទេ ដែលៗមាន -- មិនៗៗប្រព្រឹត្ត មានគោរពបទបញ្ជា ហើយបើៗៗមាន តើគេប្រព្រឹត្តទៅលើអ្នកដែលមិនគោរពបទបញ្ជាហ្នឹងយ៉ាងដូចម្តេច? នេះជាសំណួរបើកទូលំទូលាយមួយដែលមិនមែនជាប្រភេទសំណួរឧបមានវិធីទេ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ អ៊ីចឹងខ្ញុំធ្វើតាមរបៀបផ្សេងវិញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំនឹងអាននូវចម្លើយរបស់សាក្សីនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ គឺ E319/23.3.54។ សំណួរ១១៦ “លោកបានចូលរួមនៅក្នុងអង្គប្រជុំដែលណែនាំឲ្យអនុវត្តគោលនយោបាយសំខាន់ៗ <រួម>មានការបោសសម្អាតខ្មាំង និងខ្មាំងយួន។ តើមានបញ្ហាអ្វីដែរទេ បើកម្មាភិបាលណាមួយមិនអនុវត្តតាមការណែនាំបែបនោះ? ពេលនោះលោកឆ្លើយថា ខ្ញុំសូមដកស្រង់ចម្លើយ១១៦៖

"ប្រសិនបើយើងមិនធ្វើតាម អង្គការនឹងយកទៅរៀនសូត្រ និងអប់រំ។ សំណួរ១១៩៖ ជាធម្មតាបើអង្គភាពបញ្ជូនអ្នកនោះទៅអប់រំកែប្រែ និង លត់ដំ តើពួកគេត្រឡប់មកអង្គភាពដើមវិញដែរឬទេ? ចម្លើយរបស់លោក៖ ពេលនោះមិនមានអ្នកណាម្នាក់ត្រឡប់មកវិញទេ អ្នកទាំងនោះបាត់ខ្លួនរហូត។" លើកលែងតែ ជឿន ហ្នឹងដែលលោកថា គេបញ្ជូនទៅ -- គឺ ឈាន នេះដែលគេបញ្ជូនទៅកសាងព្រលានយន្តហោះនៅកំពង់ឆ្នាំង។ ក្រៅពីហ្នឹងគឺបាត់ខ្លួនទាំងអស់។ ដូច្នេះខ្ញុំចង់សួរលោកនេះ នៅពេលដែលលោកប្រើពាក្យថា "អប់រំ កែប្រែ" នេះតើមានន័យយ៉ាងម៉េច? អម្បាញ់មិញនេះ ពេលដែលនិយាយអំពីស-២១ លោកក៏និយាយថា កន្លែងហ្នឹងជាកន្លែងអប់រំកែប្រែដែរ ជាមន្ទីរអប់រំកែប្រែ។ ដូច្នេះចង់ខ្ញុំសួរលោកថា នៅពេលដែលគេបញ្ជូនអ្នកណាម្នាក់ទៅអប់រំកែប្រែហ្នឹង លោកសំដៅថាបញ្ជូនអ្នកហ្នឹងទៅមន្ទីរសន្តិសុខ <ឬក៏មានន័យថាអ្វីផ្សេងទៀត>?

[១៥:១៦:២២]

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** តាមការអនុវត្តជាក់ស្តែងដែលខ្ញុំលើកនៅក្នុងឯកសារ ខ្ញុំនិយាយសំដៅលើបុគ្គលដែលមានទោសកំហុសនៃអនុវត្តដែលបានប្រព្រឹត្តខុសឆ្គង។ អ៊ីចឹងការបញ្ជូនទៅកន្លែងអប់រំជិតឆ្ងាយ សម្រាប់អង្គ-ភាពរបស់ខ្ញុំ ខ្ញុំមិនមានទេ ប៉ុន្តែខ្ញុំឃើញអង្គភាពផ្សេងៗ ក្រៅពីអង្គភាពខ្ញុំ។ ខ្ញុំនិយាយក្នុងក្របខ័ណ្ឌថា មានអង្គភាពខ្លះបញ្ជូនទៅ ហើយពេលដែលបញ្ជូនទៅហើយ បុគ្គលនោះមិនឃើញត្រឡប់មកវិញទេ។ នេះជាការនិយាយនៅក្នុងឯកសារ។ អ៊ីចឹងអ្វីដែលខ្ញុំកំណត់សម្គាល់ គឺខ្ញុំកំណត់សម្គាល់ក្នុង ក្រៅអង្គភាព លើកឧទាហរណ៍ដែលខ្ញុំបញ្ជាក់ថា អង្គភាពខ្ញុំមិនមាននេះ ព្រោះខ្លួនខ្ញុំផ្ទាល់ នៅក្នុងការគ្រប់គ្រងនាវា ខ្ញុំមិនមានជួបប្រទះសភាពការណ៍ ហេតុការណ៍ហ្នឹងទេ តែអង្គភាពផ្សេងមាន។ នេះសូមបញ្ជាក់។

**ស៖** ដូច្នេះមានន័យថា លោកគោរពបញ្ជាយ៉ាងម៉ឺងម៉ាត់ពីថ្នាក់លើ ហើយមិនមាន លោកមិនមានករណីដែលថាលោកមិនគោរពបញ្ជាទេ។ អ៊ីចឹងមែនទេ?

**ឆ៖** នេះជាការពិត ព្រោះខ្ញុំជាមនុស្សមួយដែលធ្វើជាក់ស្តែង ហើយអ្វីដែលខ្ញុំបានធ្វើ វាជាកិច្ចការមួយដែលខ្ញុំធ្លាប់ធ្វើ ខ្ញុំបានធ្វើ ខ្ញុំកំពុងធ្វើ។ ដូច្នេះទម្លាប់នេះ វាជាការងារមួយដែលខ្ញុំមិនបានអនុវត្តអីឲ្យខុសនូវ – ពេលនោះគេហៅថា "មាគ៌ា" ទេ អង្គភាព ក៏ដូចជាខ្លួនខ្ញុំផ្ទាល់។

**ស៖** ចុះបើថ្នាក់ក្រោម ដូចលោកនៅថ្នាក់អនុសេនាធំ ឬក៏កាពីទែននាវានោះ តើពួកគេមានសិទ្ធិបញ្ចេញយោបល់ ផ្តួចផ្តើមគំនិត ឬក៏សម្រេចសំខាន់ៗនៅលើនាវា ដោយមិនពិគ្រោះយោបល់ ឬក៏សុំ

យោបល់ពីថ្នាក់លើ ដោយមិនចាំបាច់ទទួលបានការឯកភាពពីថ្នាក់លើដែរឬទេ?

[១៥:១៩:៥៧]

**ឆ៖** កិច្ចការអនុវត្តបច្ចេកទេស ខ្ញុំសូមជម្រាបថា បច្ចេកទេសបើសិនជាមានការ ខ្ញុំទាញឧទាហរណ៍ បើម៉ាស៊ីនខូច ត្រូវការជុសជុល។ អ៊ីចឹងត្រូវស្នើមតិទៅថ្នាក់វរសេនាតូច វរសេនាធំ កងពល លុះសេចក្ដីសម្រេចនេះ ត្រឡប់មកដល់ខ្លួនវិញ ទើបអនុវត្តការជុសជុល។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ ថ្ងៃស្អែកខ្ញុំនឹងនិយាយអំពីបញ្ហាដែលកើតឡើងនៅជុំវិញកោះ។ ក៏ប៉ុន្តែមុននេះ ខ្ញុំចង់និយាយអំពីពិធីបុណ្យ ឬក៏កិច្ចប្រជុំផ្សេងៗ ដែលលោកបានចូលរួមនៅទីក្រុងភ្នំពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រៅពីការប្រជុំដែលលោកបានលើកឡើងថា លោកបានប្រជុំជាមួយ សុន សេន នោះ លោកធ្លាប់ទៅភ្នំពេញក្នុងឱកាសផ្សេងទៀតទេ ឧទាហរណ៍ដូចជានៅពេលមីទ្ទិងធំៗនៃកម្មាភិបាលបក្ស ឬក៏កងទ័ពនៅស្ដាតអូឡាំពិក ឬនៅកន្លែងផ្សេងទៀត ឬក៏លោកធ្លាប់ចូលរួមក្នុងបុណ្យខួបរំឭកការជ័យជម្នះនៅភ្នំពេញថ្ងៃទី១៧ មេសា ខួបនៃការបង្កើតបក្សនៅថ្ងៃទី៣០ កញ្ញា ឬក៏ខួបនៃការបង្កើតកងទ័ពបដិវត្តកម្ពុជា ដែលធ្វើនៅខែមករា? លោកធ្លាប់ទៅភ្នំពេញ ដើម្បីចូលរួមនៅក្នុងឱកាស ឬក៏នៅក្នុងពិធីប្រជុំធំៗទាំងអស់ហ្នឹងទេ?

**ឆ៖** ការទៅចូលរួមនៅកម្មវិធីបុណ្យជាតិធំៗ ដូចជាកំណើតកងទ័ព កំណើតបក្ស កំណើតជ័យជម្នះ ១៧មេសាអី ខ្ញុំនិងអង្គភាពអត់ឡើងមកធ្វើនៅភ្នំពេញទេ គឺខ្ញុំធ្វើនៅក្រុងកំពង់សោម។ ដោយឡែកបើមានករណី ឋានៈអគ្គមេបញ្ជាការអញ្ជើញ ឋានៈកម្មាភិបាល ខ្ញុំនិយាយពាក្យធម្មតានៅពេលនោះ ថ្នាក់ស្នងការ អនុសេនាធំ ស្នងការវរសេនាតូច ស្នងការវរសេនាធំ ស្នងការកងពល ដែលឡើងមករៀនសូត្រនៅក្រុងភ្នំពេញ អាហ្នឹងទើបមក។

[១៥:២៣:២៣]

**ស៖** នៅក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅទំព័រ៩១ ជាភាសាអង់គ្លេស និងទំព័រជាភាសាខ្មែរ 00926419 លោកបាននិយាយថា លោកនៅភ្នំពេញនៅឆ្នាំ៧៦, ៧៧ ហើយថាលោកថា ពេលនោះលោកឃើញ ប៉ុល ពត ថ្លែងសុន្ទរកថា ឬក៏ធ្វើបទឧទ្ទេសនាម គឺគាត់ធ្វើហ្នឹង គឺនៅថ្ងៃទី១៧ មេសា។ លោកចាំថា លោកបានឆ្លើយអ៊ីចឹងទេ?

**ឆ៖** នៅក្នុងឯកសារដែលខ្ញុំបានចុះ ខ្ញុំបានចូលរួមមួយដងដែលបានឃើញមុខ ប៉ុល ពត គាត់បានឡើងថ្លែងការណ៍នៅទីក្រុងភ្នំពេញ កាលនោះធ្វើនៅស្ដាតអូឡាំពិក។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** លោកចាំឆ្នាំទេ <គេរៀបចំកិច្ចប្រជុំនេះ>នៅក្នុងឆ្នាំណាដែរ <ដែលលោកបានទៅភ្នំពេញនោះ>?

**ឆៈ** ខ្ញុំចាំ ប្រហែលជាឆ្នាំ៧៧។

**សៈ** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោកធ្លាប់បានស្តាប់វិទ្យុភ្នំពេញ ឬក៏អានទស្សនាវដ្តីទង់បដិវត្ត ឬយុវជនយុវនារីបដិវត្តដែរឬទេ? ក្នុងបទសម្ភាសន៍លោក គឺលោកនិយាយអំពីចំណុចនេះ។

**ឆៈ** ចំណុចនេះ ខ្ញុំបានទទួលឯកសារទស្សនាវដ្តីប្រចាំខែទង់បដិវត្តកម្ពុជា -- ទង់ក្រហមបដិវត្តកម្ពុជា ហើយនិងការស្តាប់វិទ្យុរៀងរាល់ថ្ងៃ។

**សៈ** ដូច្នេះមានន័យថា លោកជាបក្ខជន តើត្រឹមត្រូវទេ?

**ឆៈ** បាទ។

[១៥:២៥:៥៥]

**សៈ** ខ្ញុំចង់អានន្ធូវសម្រង់នៃសុន្ទរកថារបស់ ប៉ុល ពត ដែលចុះផ្សាយនៅក្នុងទស្សនាវដ្តីទង់បដិវត្តប្រហែលជាលោកធ្លាប់បានអានហើយមើលទៅ។ ខ្ញុំចង់ដឹងថាតើលោកស្គាល់ច្បាស់អំពីប្រធានបទដែលគាត់និយាយ ហើយនិងពាក្យពេចន៍ ដែលគាត់បានប្រើប្រាស់ដែរឬទេ គឺនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៨។ ឯកសារនោះគឺ E3/4604 ជាសុន្ទរកថារបស់សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជា។ ដំបូងគឺនៅទំព័រជាភាសាបារាំង 00520344, ជាភាសាអង់គ្លេសគឺ 00519833 ទៅដល់34, ជាភាសាខ្មែរគឺប្រហែលជានៅលេខ ERN 00064713 ឬក៏ 714។ នៅក្នុងសុន្ទរកថានេះ ប៉ុល ពត និយាយអំពីខ្មាំងយួន។ លោក ប៉ុល ពត បាននិយាយដូចតទៅៈ “បក្សស្នើឲ្យយើងកម្ទេចសត្រូវឲ្យបានច្រើនបំផុត ហើយបានសុំឲ្យយើងការពារកម្លាំងរបស់យើងឲ្យបានតាមដែលអាចធ្វើទៅបាន។ យើងមានគ្នាតិច ប៉ុន្តែយើងត្រូវតែកម្ទេចខ្មាំងដែលមានច្រើនជាងយើង។ ដូច្នេះយើងត្រូវតែការពារកម្លាំងរបស់យើងឲ្យបានជាអតិបរិមា ហើយនិងកម្ទេចកម្លាំងរបស់ខ្មាំងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ នេះគឺជាពាក្យស្លោកដែលផ្តោតទៅលើតួលេខ យើងម្នាក់ត្រូវតែកម្ទេចវៀតណាមឲ្យបាន៣០នាក់។ ប្រសិនបើយើងអាចធ្វើបានតាមពាក្យស្លោកនេះ យើងនឹងឈ្នះ។ ទោះបីជាយួនមានប្រជាជនប៉ុន្មាននាក់ក៏ដោយ យើងនឹងវាយយកជ័យជម្នះឲ្យបាន។ ប្រទេសណាក៏ដោយដែលឈ្លានពានកម្ពុជា ប្រសិនបើយើងអនុវត្តពាក្យស្លោកនេះបាន យើងនឹងទទួលបានជ័យជម្នះ។ រហូតមកដល់ពេលនេះ គឺយើងអាចអនុវត្តពាក្យស្លោកនេះបាន គឺថាម្នាក់ត្រូវកម្ទេច៣០នាក់ ម្នាក់ទល់នឹង៣០នាក់។” សូមបញ្ចប់ការដកស្រង់។

ក្នុងសម្រង់នេះ ប្រហែលជាលោកធ្លាប់ឮហើយគឺ ប៉ុល ពត គាត់និយាយថា ទោះបីជាជនជាតិវៀតណាមមានប៉ុន្មានក៏ដោយ ក៏យើងអាចវាយឈ្នះដែរ។ ដូច្នេះគាត់មិនបែងចែកថា តើជាទាហាន ឬក៏ជាប្រជាជនទេ ពេលនោះ។ តើលោកធ្លាប់ឮថាខ្មាំងយួននេះ គឺថាមានរួមទាំងប្រជាជនផងដែរ មិនសំដៅតែលើយោធា ឬក៏កងទ័ពទេ?

[១៥:២៩:០៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់សំណួរនេះ គឺថាឯកសារទង់បដិវត្តហ្នឹងបញ្ជាក់ច្បាស់ហើយ គឺនិយាយ<តែអំពី>កងទ័ពវៀតណាមទេ។ និយាយពីកងទ័ព គឺនិយាយដូចគ្នាបេះបិទនៅពេលដែលគាត់ផ្តល់បទសម្ភាសន៍ទៅ អេលីហ្សាប៊ែត បេកឃ័រ នៅ<ខែធ្នូ> ឆ្នាំ១៩៧៨។ <វាច្បាស់ណាស់នៅក្នុងការសម្ភាសនោះ នៅពេលដែលគាត់និយាយអំពីកងទ័ពវៀតណាម ឬយោធាវៀតណាម ឬក៏វៀតណាម ជាលក្ខណៈទូទៅដូចជាប្រទេសមួយ។ នៅក្នុង>គោលនយោបាយរបស់<គាត់ គាត់និយាយអំពី>ជនជាតិយួន។ <នៅពេលគាត់និយាយអំពីប្រជាជនវៀតណាម គាត់និយាយអំពីប្រជាជនមកពីប្រទេសវៀតណាម។> គឺគាត់បានបញ្ជាក់ពីភាពខុសគ្នាយ៉ាងជាក់ស្តែង។ ប៉ុន្តែនៅទីនេះ គឺគាត់និយាយអំពីសង្គ្រាមជាមួយវៀតណាម គឺសង្គ្រាមប្រឆាំងនឹងទាហាន កងទ័ពវៀតណាម <មិនមែនប្រជាជនស៊ីវិលនោះទេ>។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំបានអានសម្រង់មួយគឺច្បាស់ណាស់ គឺនិយាយអំពីប្រជាជនវៀតណាម។ ទោះបីជាមេធាវីការពារក្តីមានទស្សនៈយ៉ាងណាក៏ដោយ ចំពោះសុន្ទរកថានេះ ក៏ប៉ុន្តែត្រង់កន្លែងនេះ ក្នុងការដកស្រង់នេះ គឺនិយាយច្បាស់<ណាស់។ មានសម្រង់ផ្សេងទៀតដែលខ្ញុំនឹងអាន ហើយឯកសារទាំងនោះក៏>និយាយអំពីជនជាតិវៀតណាម និយាយអំពីប្រជាជនវៀតណាម មិនមែននិយាយអំពីទាហានវៀតណាមទេ។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីសួរសំណួរនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវី វ៉ិចទ័រ កូប៉េ លើការតាំងសំណួរនេះ។ សំណួរនេះមានមូលដ្ឋានត្រឹមត្រូវ។ សាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិនូវសំណួរចុងក្រោយអម្បាញ់មិញនេះ បើសិនជាលោកចាំ។ បើលោកមិនចាំ លោកអាចឱ្យសហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹងតាំង សុំសួរលោកសាជាថ្មីម្ដងទៀត ក៏បានដែរ។

[១៥:៣១:០៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ឮថា ប៉ុល ពត និយាយថា ខ្មាំងយួន គឺប្រជាជនវៀតណាម? លោកធ្លាប់ ប៉ុល ពត និយាយបែបនេះទេ?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** តាមឯកសារទង់បញ្ជាក់ហ្នឹង គឺវាជាគោលនយោបាយសំខាន់ សម្រាប់កម្មាភិបាលដែលត្រូវតែយល់ដឹង។ តែក្នុងហ្នឹងសូមបញ្ជាក់ឱ្យច្បាស់ ខ្ញុំសូមបញ្ជាក់ថា កងទ័ពយើងមួយនាក់ត្រូវកម្ទេចពួកឈ្លានពានយួនឱ្យបាន៣០ក្បាល។ នេះជាគោលដៅ ហើយនេះជាគោលនយោបាយរបស់សមមិត្តលេខា ប៉ុល ពត គាត់បាននិយាយនៅក្នុងសៀវភៅទង់ក្រហមបដិវត្ត។ នេះជាការត្រឹមត្រូវ ព្រោះពេលនោះ សត្រូវរបស់កម្ពុជាប្រជាធិបតេយ្យមានមហិច្ឆតាធំធេង។ ដោយខ្ញុំយល់ឃើញដូចសមមិត្តលេខាដែរ ព្រោះថាប្រទេសចំប៉ា យួនលេបហើយ កម្ពុជាក្រោម យួនលេបហើយ អ៊ីចឹងសល់កម្ពុជាលើ ខ្ញុំក៏មានជំនឿថាវានឹងមានផែនការបន្តទៀត។ តែមកដល់បច្ចុប្បន្ននេះ ខ្ញុំកំណត់ថាគេមិនភ្លេចទេយុទ្ធសាស្ត្រតែឥឡូវប្រជាជនកម្ពុជា ខ្ញុំក្នុងនាមជាជនជាតិកម្ពុជាមួយរូប ខ្ញុំក៏នៅមានគំនិតនេះថា គេមិនបោះបង់។ នេះជាមហិច្ឆតា។ សូមអស់មតិ។

[១៥:៣៣:១៧]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី ហើយយើងណែនាំលោកថា គប្បីលោកព្យាយាមឆ្លើយតបទៅនឹងសំណួរដែលសួរ ហើយកម្រិតត្រឹមតែភាពចាំបាច់ឆ្លើយតបនឹងសំណួរបានហើយ ជៀសវាងលោកផ្ដល់នូវគំនិតយោបល់និងការយល់ឃើញផ្ទាល់ខ្លួន ព្រោះសាក្សីមិនអាចផ្ដល់នូវការគំនិតយោបល់ផ្ទាល់ខ្លួនដែលមានប្រយោជន៍ដល់ការស្វែងរកការពិតទេ នោះជាគំនិតអត្តនោម័តរបស់បុគ្គល។ ហើយសូមស្ដាប់សំណួរឱ្យបាន ហើយឆ្លើយតបពេញលេញនូវសំណួរហ្នឹងបានហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅក្នុងសុន្ទរកថានេះគឺ ប៉ុល ពត បាននិយាយអំពីថា <>មួយត្រូវវាយតទល់ជាមួយនឹងទាហាន៣០នាក់ <គឺសំដៅទៅលើទាហានវៀតណាម។ ជាការពិត គឺសំដៅទៅលើទាហាន ប៉ុន្តែ ប៉ុល ពត ក៏សំដៅទៅលើចំនួន>ប្រជាជនខ្មែរ២លាននាក់ <ដែលអាចគ្រប់គ្រាន់ដើម្បី>កម្ទេចវៀតណាម <៦០លាននាក់។>

**ប្រធានអង្គជំនុំ៖**

ឈប់ៗ!

យ៉ាងម៉េចទៅលោកមេធាវី រ៉ិចឆ័រ កូប៉េ?

**លោក រ៉ិចឆ័រ កូប៉េ៖**

<គាត់បន្តធ្វើឲ្យ>លោកប្រធាន<យល់ច្រឡំហើយ។ គាត់កំពុង>និយាយអំពី<កងទ័ពវៀតណាម៣០នាក់ គឺទាហាន>១ទល់នឹង៣០។ <នោះគឺជាចំនួនដែល>កងទ័ពវៀតណាម<មានច្រើនជាង។> គឺមិននិយាយទាល់តែសោះអំពីជនជាតិវៀតណាមជាជនស៊ីវិលនោះទេ។ អ៊ីចឹង<គាត់ពិតជាធ្វើឲ្យលោកប្រធានយល់ច្រឡំហើយ>។

[១៥:៣៥:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់ ពីព្រោះថា នៅក្នុងឯកសារដែលព្រះរាជអាជ្ញាបានដកស្រង់ ហើយខ្ញុំក៏បានអានជាភាសាបារាំងដែរ គឺមានការបកប្រែពាក្យ "យួន" ដែលបកទៅជា<ភាសាបារាំងថា>"ប្រជាជនវៀតណាម" ក៏ប៉ុន្តែនៅក្នុងភាសាអង់គ្លេស ហើយនិងភាសាខ្មែរ គឺយើងឃើញថាមានពាក្យពិតប្រាកដនោះគឺពាក្យ "យួន" <>មិនបានប្រើថាជាប្រជាជនវៀតណាមទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់សូមបញ្ជាក់ទៅលើអត្ថបទនេះ ដែលយើងដកស្រង់ពី

ភាសាខ្មែរជាភាសាដើម។ អ៊ីចឹងនៅក្នុងភាសាដើមនេះ គឺបញ្ជាក់ទៅលើកងទ័ពនេះច្បាស់ណាស់ មិនមែនទៅលើប្រជាជនវៀតណាម ឬក៏យួនទេ។ ហើយការប្រើពាក្យ វាអាចក្នុងខ្លឹមសារខ្លះ ឧទាហរណ៍ថា ខាងយួនខូចខាត អ៊ីចឹងវាអត់មានពាក្យថា កងទ័ពយួនទេ ប៉ុន្តែជាន័យរួម ពីតួលេខដែលត្រូវបញ្ជាក់នៅក្នុងខ្លឹមសារ គឺបញ្ជាក់ពីកងទ័ព។ កងទ័ពខ្មែរម្នាក់វ៉ៃយួន៣០នាក់ ឬក៏កងទ័ពខ្មែរ១លាននាក់ វាយយួន៣០លាននាក់។ បាទ នេះជាតួលេខដែលបញ្ជាក់ច្បាស់។ សូមអរគុណ។

[១៥:៣៦:៤៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន តើខ្ញុំអាចបន្តបានទៀតទេ? ខ្ញុំមិនមានអ្វីយោងច្បាស់លាស់ទេ ក៏ប៉ុន្តែខ្ញុំនឹងស្វែងរក ហើយខ្ញុំនឹងផ្តល់ជូននៅថ្ងៃស្អែក។ ព្រោះថានៅក្នុងហ្នឹង គេនិយាយថា ប៉ុល ពត ថាខ្មែរ២លាននាក់អាចកម្ទេចវៀតណាម៦០លាននាក់ <ហើយ៦លាននាក់ អាចនឹងត្រូវចាកចេញ>។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** ដូច្នេះលោកសាក្សី លោកធ្លាប់ឮពាក្យហ្នឹងពីមាត់របស់ ប៉ុល ពត ទេ?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** ការពិត នេះជាការប្រៀបធៀបកម្លាំងយោធា ១ទល់៣០។ ដូច្នេះក្នុងឯកសារនេះ គឺបញ្ជាក់ច្បាស់ ខ្ញុំនៅតែចាប់យកថា ជាឯកសារដែលគាត់បានលើក ដោយឲ្យកងទ័ពទាំងអស់ចេះពិចារណាក្នុងយុទ្ធវិធីប្រយុទ្ធវាយកម្ទេចសត្រូវ។

**ស៖** ដូច្នេះមានន័យថា ប្រជាជនវៀតណាមទាំងអស់ហ្នឹង៦០លាន គឺមានន័យថា សុទ្ធតែជាយោធាហើយ មែនទេ? ព្រោះថាក្នុងនេះលោក ប៉ុល ពត គាត់និយាយថា ១<សែន>នាក់ខ្មែរ អាចទប់ទល់នឹង<១>លាន<នាក់>វៀតណាម។ <>អ៊ីចឹងមានន័យថា នៅវៀតណាម៦០លាននោះ សុទ្ធតែយោធាទាំងអស់ មែនទេ?

**ឆ៖** តាមពិត មិនមែនកងទ័ពវៀតណាមមានដល់៦០លាន ហើយកងទ័ពខ្មែរ កម្ពុជាប្រជាធិបតេយ្យមាន២លានទេ ពេលនោះ។ ប៉ុន្តែគ្រាន់តែជាអ្វីដែលឲ្យកម្មាភិបាលយុទ្ធជនចេះ គេហៅថា យល់ពីវិធី និងរៀបចំមាគ៌ាសកម្មភាពក្នុងការប្រយុទ្ធដំណើរការដណ្តើមយកជ័យជម្នះ។

[១៥:៣៩:១៥]

**ស៖** សូមអរគុណ។ ខ្ញុំសូមទុកសម្រង់នេះ មួយឡែកសិន។ ខ្ញុំសូមដកស្រង់មួយទៀត ជាភាសា

បារាំងគឺ 00520348, ជាភាសាអង់គ្លេសគឺ 00519836 និងជាភាសាខ្មែរគឺ 00064717។ ប៉ុល ពត បាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់៖ “ពីដើមមកយួនវាយឈ្នះយើងទេ? យួនវាចង់បានកម្ពុជាធ្វើជារណបវា តាំងពីឆ្នាំ១៩៣០។” សូមរំលងបន្តិច៖ “ឆ្នាំ៧០ វាយកកម្ពុជាបានទេ? វាយកអត់បានទេ ឆ្នាំ៧៥ វាយកកម្ពុជាបានទេ? វាអត់យកបានទេ រហូតដល់ឥឡូវយួនយ៉ាងម៉េច? យួនអត់នៅក្នុងទឹកដីកម្ពុជា ពីដើមជិត១លាននាក់ ឥឡូវរកមួយគ្រាប់គ្មានទេ។” ខ្ញុំសូមបន្តទៀត៖ “ដូច្នេះទស្សនៈរបស់យើងកុំចុះញ៉មមុន”។ លោកសាក្សីតើលោកធ្លាប់ស្ដាប់ឮ ប៉ុល ពត ឬក៏មេដឹកនាំបក្ស ឬថ្នាក់ដឹកនាំកងពល១៦៤ ធ្លាប់បានលើកឡើងអំពីវិធានការក្នុងការកម្ទេចវៀតណាមដែលនៅរស់នៅទីក្រុងភ្នំពេញ មុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ដែរឬទេ?

**ឆ៖** តាមខ្ញុំយល់ ហើយស្ដាប់នូវសម្ដីដែលគាត់លើកក្នុងឯកសារនេះ គឺជាឆន្ទៈនយោបាយសម្រាប់បំផុសដល់កម្មាភិបាលយុទ្ធជន ឲ្យមានទឹកចិត្តនិងលើកស្ទួយខាងស្មារតី ឲ្យមានស្មារតីត្រៀមខ្លួនប្រយុទ្ធក្នុងកាលៈទេសៈណាមួយដែលវានឹងកើតឡើងចំពោះកម្ពុជា ភាគីវៀតណាម និងកម្ពុជាប្រយុទ្ធគ្នា។ នេះជាការជាក់ស្ដែងដែលគាត់លើកធ្វើគោលនយោបាយបង្ហាញផ្លូវ។

[១៥:៤២:៣៧]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងគាត់និយាយថា វៀតណាមហ្នឹងគឺនៅកម្ពុជាជិត១លាននាក់ តាំងពីមុនពេល ប៉ុល ពត <ឡើងកាន់កាប់អំណាច> ហើយក្រោយមកនៅសល់មួយគ្រាប់គ្មានផង។ ដូច្នេះ តើគាត់មាននិយាយអំពីវិធានការអ្វី ឧទាហរណ៍ ដូចជាការបញ្ជូនវៀតណាមទៅកាន់ប្រទេសវៀតណាមវិញ <ដោយថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ> ដែរទេ នៅដើមរបបខ្មែរក្រហមនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់នឹងទម្រង់នៃការសួរនេះលោកប្រធាន។ សហព្រះរាជអាជ្ញា គឺថាទុកជម្រើសតែមួយទាក់ទងទៅនឹងមូលហេតុ<ថាមាន>ជនជាតិវៀតណាម<មួយចំនួនតិចតួច>នៅក្នុងឆ្នាំ១៩៧៥។ ប៉ុន្តែមានអ្នកជំនាញច្រើនណាស់ដែលរៀបរាប់អំពីការជម្លៀស<ជនជាតិវៀតណាម>ចេញជាច្រើនដោយរដ្ឋាភិបាល លន់ នល់ មុនឆ្នាំ១៩៧៥។ អ៊ីចឹងដើម្បីឲ្យត្រឹមត្រូវនិងយុត្តិធម៌ គឺថាត្រូវតែដាក់បញ្ចូល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្លឹមសារដែល លន់ នល់ ជម្លៀសចេញហ្នឹង ចូលក្នុងសំណួររបស់សហព្រះរាជអាជ្ញាផង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិននិយាយអំពីហេតុការណ៍ដែលកើតឡើងមុនរបបនេះទេ។ យើងដឹងថាពីមុនហ្នឹងមានវិធានការរបស់ លន់ នល់ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមដែរ ប៉ុន្តែនេះមិនមែនជាគោលបំណងនៃសំណួរខ្ញុំទេ។ ខ្ញុំសួរអំពីវិធានការដែលរៀបចំឡើងដោយរដ្ឋាភិបាល ឬក៏រដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម។

[១៥:៤៤:២០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា លោកមេធាវី វ៉ិចទ័រ កូប៉េ នូវបញ្ហានេះ។ សំណួរនេះគឺត្រឹមត្រូវសមស្របហើយ។ សាក្សីឆ្លើយតបនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ដែលសួរលោកអម្បាញ់មិញនេះ។

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** សូមឆ្លើយតបនឹងសំណួរនេះ។ ខ្ញុំចាំឆ្នាំមិនបាន ក្នុងវិធានដែលរៀបចំបញ្ជូនជនជាតិយួនវិលត្រឡប់ទៅស្រុកវិញ មិនដឹងថាជាឆ្នាំណា ខ្ញុំមិនចាំទេ។ តែខ្ញុំដឹងថាមានបញ្ជូនជនជាតិយួន នៅឆ្នាំ១៩៧៣ម្ដង ពេលដែលប្រយុទ្ធសម័យនោះ ក៏មានការប្រយុទ្ធដែរ។ ហើយនៅឆ្នាំ១៩៧៥ ឬ៧៦ ខ្ញុំមិនច្បាស់ សូមអធ្យាស្រ័យ តែមានការបញ្ជូនជនជាតិយួនវិលត្រឡប់ទៅស្រុកយួនវិញ ក្នុងនាមជារដ្ឋា-ភិបាលកម្ពុជាប្រជាធិបតេយ្យពេលនោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើវៀតណាម ដែលមិនត្រូវបានបញ្ជូនទៅវៀតណាមវិញនៅក្នុងឆ្នាំ៧៥ <និង>៧៦នុំង ត្រូវបានរដ្ឋអំណាចខ្មែរក្រហមបង្ក្រាបទេ នៅក្នុងឆ្នាំ៧៧ <និង> ៧៨ <នៅក្នុងប្រទេស>នោះ? ខ្ញុំសំដៅ<លើប្រជាជន>វៀតណាមដែលនៅកម្ពុជាតាំងពីមុនមកនោះ ហើយមិនត្រូវបានបញ្ជូនទៅស្រុកវិញនេះ នៅក្នុងឆ្នាំ៧៥, ៧៦ តើឆ្នាំ៧៧, ៧៨ ហ្នឹងខ្មែរក្រហមបានបង្ក្រាបវៀតណាមទាំងអស់ហ្នឹងទេ?

**ឆ៖** កិច្ចការហ្នឹងខ្ញុំសូមមិនឆ្លើយតប ព្រោះខ្ញុំមិនបានអនុវត្ត ព្រោះភារកិច្ចរបស់ខ្ញុំនៅខាងសមុទ្រអត់ដឹងរឿង។

[១៥:៤៦:៣០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំឆ្លើយអ៊ីចឹង បើលោកថាមិនដឹង គឺលោកឆ្លើយថាមិនដឹងទេ។ លោកមិនអាចឆ្លើយថាមិនឆ្លើយតបនឹងសំណួរបានទេ។ យើងបានប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងការឆ្លើយតបនឹងសំណួរតាំងពីដើមដំបូង គឺមានកាតព្វកិច្ចត្រូវតែឆ្លើយតបរាល់សំណួរដែលសួរ លើកលែងតែសំណួរហ្នឹងនាំឲ្យដាក់បន្ទុកលើខ្លួនឯង។ ហើយសំណួរ -- បើចម្លើយរបស់លោកឆ្លើយថាមិនដឹង ក៏ជាចម្លើយតបដែរ លោកយល់ដែរទេ?

**លោក ព្រុំ សារ៉ាត៖**

**ឆ៖** ខ្ញុំសូមកែពាក្យវិញ ដោយខ្ញុំប្រើពាក្យថា ពេលនោះខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅបំពេញភារកិច្ចកន្លែងផ្សេង ឆ្ងាយ មិនមែនជាក្របខ័ណ្ឌខ្ញុំអនុវត្តទូទាំងប្រទេស ដូចសំណួរលោកដែលបានបញ្ជាក់មករូបខ្ញុំ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយជ៍ ដេស្នាឯល៖**

**ស៖** សម្រង់ចុងក្រោយនៃសុន្ទរកថារបស់ ប៉ុល ពត គឺនៅលេខ ERN ជាភាសាបារាំងគឺ 00520351, ERN ជាភាសាអង់គ្លេសគឺ 00519838 រហូតទៅដល់39, ជាភាសាខ្មែរគឺ 00064720។ ខ្ញុំសូមដកស្រង់នូវសុន្ទរកថារបស់ ប៉ុល ពត៖"វៀតណាមវាចង់បន្តទៀត វាថាទទួលស្គាល់ព្រំដែនគោក វាទទួលស្គាល់ព្រំដែនកោះ ប៉ុន្តែវាមិនទទួលស្គាល់ព្រំដែនសមុទ្រទេ។ ព្រំដែនសមុទ្រសុំចរចារគ្នាទៀត។ បក្សកំណត់ថាវាយវាទៀត វាយវាទៀតទាល់តែទទួលទាំងព្រំដែនសមុទ្រ និងព្រំដែនអាកាសទៀត។ ទាល់តែវាយ១ទល់នឹង៣០តទៅទៀត បានវាទទួលស្គាល់ ហើយទទួលស្គាល់ទាំងក្រដាសផង ទទួលស្គាល់ទាំងលើឆាកអន្តរជាតិផង ហើយមិនហ៊ានមកបៀតព្រំដែនយើងទៀត។ ទាល់តែវាយវាទៀត ភារកិច្ចរបស់យើង ការពារតទៅទៀត ទាល់តែវាយទៀត។" សូមបញ្ចប់ការដកស្រង់។

[១៥:៥៩:១២]

ពាក់ព័ន្ធទៅនឹងព្រំដែនសមុទ្រនៅសម័យនោះ ពេលដែលលោកធ្វើការនៅក្នុងកងពល១៦៤ ហើយនិងនៅក្នុងវរសេនាធំ១៤០នោះ តើត្រឹមត្រូវដែរឬទេ តាមរយៈសុន្ទរកថារបស់វៀតណាមនោះ -- របស់ ប៉ុល ពត នោះ (សូមទោស) គឺថាព្រំដែនសមុទ្រដែលទទួលស្គាល់ដោយកម្ពុជាហ្នឹង វាមិនដូចទៅនឹងព្រំដែនសមុទ្រដែលទទួលស្គាល់ដោយវៀតណាមទេ? តើវាមានភាពខុសគ្នាទេ? គឺខ្ញុំសំដៅទៅលើចម្ងាយនៃដែនទឹកកម្ពុជានោះ តើមានការជជែកតវ៉ាគ្នា រវាងកម្ពុជានិងវៀតណាមទេ ពាក់ព័ន្ធទៅនឹងដែន

ទឹកនោះ?

**ឆ៖** តាមការពិតកិច្ចការហ្នឹងខ្ញុំមិនបានដឹងទេ ព្រោះវាជាកិច្ចការរបស់ថ្នាក់ដឹកនាំខាងលើ។ និយាយឲ្យចំ គឺជាភារកិច្ចរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងជាភារកិច្ចរបស់រដ្ឋាភិបាលវៀតណាម។

**ស៖** តើ<វាបានកើតឡើងទេ នាវិកជនជាតិ>វៀតណាមដែលត្រូវបានចាប់នៅ<លើទូកជិតកោះ>កម្ពុជា <>បានតវ៉ាថា <>ពួក<គេ>នៅក្នុងដែនទឹកកម្ពុជា<>?

**ឆ៖** អ្វីដែលខ្ញុំបញ្ជាក់ ខ្ញុំសូមបញ្ជាក់ថា កងទ័ពដែលខាងខ្ញុំទទួលបានតាមព័ត៌មាន តាមវិទ្យុទាក់ទង ថាចាប់បានកងទ័ពវៀតណាម ឬក៏ទូកវៀតណាមដែលចូលមកដល់ទឹកដីកម្ពុជា ដូចជាខ្ញុំបញ្ជាក់ជូនសំណួរខាងដើមមួយថា មានថ្ងៃមួយនោះ ខ្ញុំជួបជនជាតិយួនម្នាក់ និងជនជាតិក្លឹងម្នាក់ ដែលនៅលើកោះ ផៃកោះតាង។ គឺការចាប់ហ្នឹង គឺខ្ញុំគ្រាន់តែសួរថា ទាហានដែលនៅជិតទាហាន -- នៅជិតជនជាតិយួន និងជនជាតិក្លឹងហ្នឹង ខ្ញុំសួរថា "គេចាប់គេមកពីណា? គេថា ចាប់នៅកោះអាគ្នេយ៍"។ កោះអាគ្នេយ៍ហ្នឹង បើលោកមើលក្នុងផែនទី លោកដឹងថាតើចម្ងាយប៉ុន្មានពីកោះតាង ហើយចម្ងាយប៉ុន្មានពីដែនទឹករបស់វៀតណាម។ ហ្នឹងតាមដែលខ្ញុំស្គាល់នៅលើផែនទី មិនមែន--។ អ្វីដែលខ្ញុំបញ្ជាក់ពេលនេះគ្រាន់តែថា អ្នកដែលចាប់ហ្នឹង ទៅចាប់ពីណាមក ចាប់ពីដែនទឹកវៀតណាម ឬចាប់នៅដែនទឹកកម្ពុជា។ សូមបញ្ជាក់ប៉ុណ្ណឹង។

[១៥:៥២:៣៨]

**ស៖** ដូច្នេះលោកមិនច្បាស់ទេថា មានការចាប់ខ្លួននៅក្នុងដែនទឹកកម្ពុជា<ទេ>។ ដូច្នេះ<តើ>លោកធ្លាប់ឮ<ឧទាហរណ៍ប្រហាក់ប្រហែលគ្នានេះ ដែល>ថា មានការចាប់នាវា ឬក៏ចាប់ទូកដែល<មិនច្បាស់ថាទូក ឬនាវាទាំងនោះស្ថិត>នៅក្នុងដែនទឹក<នៃប្រទេសណាមួយឲ្យច្បាស់លាស់នោះ>?

**ឆ៖** ការទទួលបានព័ត៌មាន ខ្ញុំតែងតែទទួល។ តែខ្ញុំទទួលនេះទទួលតាមណា គឺទទួលតាមរលកវិទ្យុទាក់ទងរវាងថ្នាក់វរសេនាធំ ពេលដែលខ្ញុំនៅប្រចាំលើនាវា។ ហើយសេចក្ដីណែនាំនេះ គឺចេញពីវរសេនាធំខ្ញុំមកវិញថា ឲ្យខ្លួនខ្ញុំត្រូវប្រុងប្រយ័ត្ន ព្រោះតាមព័ត៌មានដែលនៅខាងកោះគេឲ្យដឹង ថាមានទូកយួនចូលមកសំដៅដែនទឹកយើង ម្ដុំកោះអាគ្នេយ៍ ឬកោះតាង ឬកោះពូលូវៃ។ នេះជាការបញ្ជាក់ ជាប្រចាំ រៀងរាល់យប់ និងរៀងរាល់ថ្ងៃរបស់មេបញ្ជាការថ្នាក់កងវរសេនាធំ ដែលគ្រប់គ្រងនាវា ឲ្យនាវាដែលនៅប្រចាំលើផ្ទៃសមុទ្រហ្នឹងប្រុងប្រយ័ត្ន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ដើម្បីបំភ្លឺឲ្យបានច្បាស់ ជាភាសាបារាំង ខ្ញុំឮពាក្យថា "ក្លឹង" <ខ្ញុំមិនដឹងច្បាស់ថា ខ្ញុំបានស្តាប់ត្រឹមត្រូវ ឬក៏អត់នោះទេ។ តើវាសំដៅទៅជនជាតិឥណ្ឌាម្នាក់ឬ? ហើយនេះគឺជាអ្វីដែលត្រូវបានកត់ត្រានៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា>។ ក្លឹងហ្នឹងមានន័យថាជាជនជាតិឥណ្ឌាមែនទេ <ឬក៏អ្នកណាម្នាក់ដែលមានរូបរាងដូចទៅនឹងឥណ្ឌា> នៅពេលដែលលោកនិយាយពាក្យថា "ក្លឹង"ៗហ្នឹង?

**ឆ៖** ខ្ញុំអត់ច្បាស់ទេ ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ថា ខ្ញុំបានសួរកងទ័ពដែលឈរនៅជិតគេទាំងពីរនាក់ហ្នឹង ព្រោះខ្ញុំមិនបាននិយាយជាមួយជនជាតិវៀតណាមមួយហ្នឹងទេ ហើយជនជាតិក្លឹងហ្នឹងមួយទេ។ ខ្ញុំដើរឆ្លងកាត់ដោយខ្ញុំទៅបំពេញភារកិច្ច ហើយខ្ញុំត្រឡប់មកវិញ។ នេះវាជាការងារដែលៗខ្ញុំមិនច្បាស់ថាតើក្លឹងហ្នឹងជាអម្បូរឥណ្ឌា ឬមួយអម្បូរណា ខ្ញុំអត់ច្បាស់។

[១៥:៥៥:៣៤]

**ស៖** សូមអរគុណ។ ខ្ញុំសូមឲ្យលោកឆ្លើយខ្លីៗបានហើយ ពីព្រោះពេលវេលាខ្លីណាស់។ ពេលដែលលោកឃើញ ប៉ុល ពត ធ្វើសុន្ទរកថានៅថ្ងៃទី១៧ មេសាហ្នឹង លោកគិតថានៅឆ្នាំ៧៧។ អ៊ីចឹងពេលហ្នឹងលោកមានបានឃើញ ខៀវ សំផន ទេ?

**ឆ៖** ពេលនោះ លោក ខៀវ សំផន គាត់អត់អញ្ជើញមកទេ។

**ស៖** ចុះលោកធ្លាប់ឃើញលោក ខៀវ សំផន ឡើងថ្លែងសុន្ទរកថានៅក្នុងឱកាសណាមួយផ្សេងទៀតទេ?

**ឆ៖** តាមខ្ញុំចាំ លោក ខៀវ សំផន គាត់ថ្លែងសុន្ទរកថាបញ្ជូនសំឡេងតាមវិទ្យុ។ ខ្ញុំស្តាប់វិទ្យុរាល់បុណ្យជាតិរៀងរាល់ឆ្នាំ មិនមានបានទៅស្តាប់គាត់ថ្លែងការណ៍ដោយផ្ទាល់មាត់ទេ ព្រោះចាក់ផ្សាយតាមតែវិទ្យុសំឡេង។ កាលហ្នឹង យើងចាក់នៅប៉ុស្តិ៍ស្ទឹងមានជ័យ។

**ស៖** ក៏ប៉ុន្តែនៅចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជានោះ លោកបានផ្តល់បទសម្ភាសន៍ថាលោកបានឃើញលោក ខៀវ សំផន ឡើងថ្លែងសុន្ទរកថា ហើយក៏លោកក៏បាននិយាយថាឃើញ ប៉ុល ពត ផងដែរថ្លែងសុន្ទរកថា។ ដូច្នេះលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ថាលោកមិនធ្លាប់ឃើញលោកខៀវ សំផន ទេនៅភ្នំពេញនោះ? ខ្ញុំសូមបញ្ជាក់ គឺទំព័រ៩១ជាភាសាអង់គ្លេស, ជាភាសាខ្មែរគឺ ERN 00926419។ "ខ្ញុំបានឃើញគាត់ឡើងថ្លែងសុន្ទរកថានៅលើឆាកវេទិកា"។

[១៥:៥៧:៥៧]

**ឆ៖** តាមការពិត ការជួប ហើយនិងការនិយាយនៅក្នុងឯកសារដែលខ្ញុំបាននិយាយជាលំដាប់ៗ ពេលនោះ ខ្មែរអាត់ពេលនុ៎ង មកសួរខ្ញុំនៅឆ្នាំ២០០៧។ គិត២០០៧ ដល់ឆ្នាំ៧៥ ហើយសភាពការណ៍ត្រឡប់ទៅក្រោយវិញ វែងឆ្ងាយ។ ដូច្នេះខ្ញុំគិតថា ចម្លើយរបស់ខ្ញុំជាមួយមជ្ឈមណ្ឌលឯកសារពេលនោះ គឺវាជាការមួយដែលខ្ញុំមិនបានព្រាងទុកផង។ ដូច្នេះឮតែសំណួរ ខ្ញុំក៏ឆ្លើយ ឆ្លើយដោយមិនបានពិចារណាថា តើអ្នកណាជាអ្នកណា ព្រោះពេលវេលាវាឆ្ងាយពេក។ នេះខ្ញុំសូមបញ្ជាក់ឲ្យលោកជ្រាប។

**ស៖** ពេលដែលលោកស្ដាប់ឮ ខៀវ សំផន ថ្លែងសុន្ទរកថាតាមវិទ្យុ ជាពិសេសនៅឆ្នាំ៧៨នោះ ក្រោយពីវៀតណាមបានវាយចូលកម្ពុជានៅចុងឆ្នាំ៧៧នោះ តើនៅឆ្នាំ៧៨ហ្នឹង តាមវិទ្យុហ្នឹងលោក ខៀវ សំផន បាននិយាយអ្វីពាក់ព័ន្ធទៅនឹងសង្គ្រាមជាមួយវៀតណាមទេ?

**ឆ៖** តាមការចាំរបស់ខ្ញុំ គឺការប្រកាសរបស់លោក ខៀវ សំផន ពេលនោះ គាត់ប្រកាសឲ្យកងទ័ពត្រៀមខ្លួន ហើយរៀបចំខ្លួនដើម្បីប្រយុទ្ធជាមួយសត្រូវដែលចូលមកឈ្លានពាន។ អ៊ីចឹងអ្វីដែលៗកើតមាន គឺវាជាការប្រកាសសម្រាប់ជម្រាបដល់ជនរួមជាតិទូទាំងប្រទេសឲ្យជ្រាប។ នេះជាវេទិកាសាធារណៈ ក្នុងនាមជាប្រមុខរដ្ឋមួយដែលគាត់ជាអ្នកដឹកនាំជាន់ខ្ពស់ ពេលនោះ។

**ស៖** បាទ សូមអរគុណ។ លោកក៏បាននិយាយអំពីសុន្ទរកថាដែល ខៀវ សំផន បានថ្លែងពាក់ព័ន្ធទៅនឹងហេតុការណ៍ចាប់កប៉ាល់<អាមេរិក គឺ>ម៉ាយ៉ាហ្គេស។ ដូច្នេះពេលនោះ តើលោក ខៀវ សំផន មានបាននិយាយថា ពួកអាមេរិកាំងបាននិយាយថា ពួកគេវង្វេងនៅក្នុងដែនទឹកកម្ពុជាដែរឬទេ? ពេលនោះ តើលោក ខៀវ សំផន គាត់បាននិយាយអ្វីខ្លះ?

[១៦:០១:១២]

**ឆ៖** ខ្ញុំចាំបាន ពេលនោះមិនមែនលោក ខៀវ សំផន ថានាវាអាមេរិកាំងវាវង្វេងទេ តែសម្ដីនាវាជាៗប្រធាន ឬក៏ថាជាសាព័ត៌មានណាមួយទេ ដែលសម្ដែងថានាវានេះ ជានាវាវង្វេងចូលមកដែនទឹកកម្ពុជា។ ដូច្នេះលោក ខៀវ សំផន ថ្លែងការណ៍ពេលនោះ គាត់កំណត់បញ្ជាក់ចំណាំច្បាស់ថា ពេលនោះ អាមេរិកាំងមានឧបករណ៍ទំនើបៗច្រើនរាប់មិនអស់។ ដូច្នេះអាមេរិកាំង មិនគួរណាប្រើពាក្យថា នាវាម៉ាយ៉ាហ្គេសរបស់អាមេរិកាំងនេះ វាវង្វេងចូលដែនទឹកកម្ពុជាឡើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៧

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខែមករា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ព្រុំ សារ៉ាត និងមានសាក្សីបម្រុងមួយរូបមានរហស្សនាម 2-TCW-849 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ព្រុំ សារ៉ាត។ ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោក ឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះក៏អញ្ជើញលោកមកចូលរួមប្រឹក្សាសាក្សីរូបនេះ ដែលនឹងធ្វើនៅសវនាការនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ព្រុំ សារ៉ាត ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកចូលរួមសវនាការវិញ នៅថ្ងៃស្អែក ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ជាកំណត់។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*